## នាយករដ្ឋមន្ត្រីកម្ពុជា, ២០២៣-០០៣-FB-MR

សេចក្ដីសង្ខេបអំពីសំណុំរឿងៈ

ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យបានបដិសេធសេចក្ដីសម្រេចរបស់ Meta ក្នុងការបន្តរក្សាទុកវីដេអូនៅលើ Facebook ដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គំរាមគូប្រជែងនយោបាយរបស់គាត់ដោយហិង្សា។ ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃការរំលោភបំពាន ប្រវត្តិរបស់លោក ហ៊ុន សែន ធ្លាប់ប្រព្រឹត្តការរំលោភបំពានសិទ្ធិមនុស្ស និងការបំភិតបំភ័យគូប្រជែងនយោបាយ ក៏ដូចជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមជាយុទ្ធសាស្ត្រដើម្បីផ្សព្វផ្សាយការគំរាមកំហែងបែបនេះ ក្រុមប្រឹក្សាភិបាលសូមអំពាវនាវ Meta ឱ្យផ្អាកជាបន្ទាន់នូវទំព័រ Facebook និងគណនី Instagram របស់លោក ហ៊ុន សែនរយៈពេលប្រាំមួយខែ។

**អំពីសំណុំរឿង**

កាលពីថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២៣ វីដេអូផ្សាយផ្ទាល់មួយត្រូវបានផ្សាយចេញពីទំព័រ Facebook ផ្លូវការរបស់នាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន។

វីដេអូនេះបង្ហាញពីសុន្ទរកថារយៈពេលមួយម៉ោង ៤១ នាទី ដែលថ្លែងដោយលោក ហ៊ុន សែន ជាភាសាខ្មែរ ដែលជាភាសាផ្លូវការរបស់កម្ពុជា។ ក្នុងសុន្ទរកថានោះ គាត់ឆ្លើយតបនឹងការចោទប្រកាន់ថា គណបក្សប្រជាជនកម្ពុជា (CPP) ដែលកំពុងកាន់អំណាចបានលួចសន្លឹកឆ្នោតក្នុងអំឡុងពេលបោះឆ្នោតមូលដ្ឋានក្នុងប្រទេសនៅឆ្នាំ ២០២២។ គាត់អំពាវនាវឱ្យគូប្រជែងនយោបាយរបស់គាត់ដែលបានធ្វើការចោទប្រកាន់នោះជ្រើសរើសរវាង “ប្រព័ន្ធផ្លូវច្បាប់” និង “ដំបង” និងនិយាយថាពួកគាត់អាចជ្រើសរើសប្រព័ន្ធច្បាប់ ឬក៏គាត់ “នឹងប្រមូលផ្ដុំមនុស្សរបស់គណបក្សប្រជាជនកម្ពុជាដើម្បីតវ៉ា និងវាយទាត់ធាក់អ្នក”។ គាត់ក៏បានលើកឡើងអំពី “ការបញ្ជូនក្មេងទំនើងទៅផ្ទះ [របស់អ្នក]” ហើយនិយាយថាគាត់អាចនឹង “ចាប់ជនក្បត់ដោយមានភស្តុតាងគ្រប់គ្រាន់នៅពាក់កណ្ដាលអធ្រាត្រ”។ ទោះជាយ៉ាងណា ក្រោយមកក្នុងសុន្ទរកថា គាត់និយាយថា “យើងមិនញុះញង់ប្រជាជន និងលើកទឹកចិត្តប្រជាជនឱ្យប្រើកម្លាំងទេ”។ បន្ទាប់ពីការផ្សាយផ្ទាល់ វីដេអូនេះត្រូវបានបង្ហោះដោយស្វ័យប្រវត្តិនៅលើទំព័រ Facebook របស់លោក ហ៊ុន សែន ដែលមានអ្នកចូលមើលប្រមាណ ៦០០.០០០ ដង។

អ្នកប្រើប្រាស់បីនាក់បានរាយការណ៍វីដេអូនេះប្រាំដងនៅចន្លោះថ្ងៃទី ៩ ខែមករា ដល់ថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០២៣ សម្រាប់ការបំពានលើស្តង់ដារសហគមន៍ស្ដីពីអំពើហិង្សា និងការញុះញង់របស់ Meta។ ស្តង់ដារនេះហាមឃាត់

“ការគំរាមកំហែងដែលអាចបណ្តាលឱ្យមានការស្លាប់” (អំពើហិង្សាកម្រិតធ្ងន់ធ្ងរ) និង “ការគំរាមកំហែងដែលនាំឱ្យមានរបួសធ្ងន់ធ្ងរ (អំពើហិង្សាពាក់កណ្តាលធ្ងន់ធ្ងរ)” រួមទាំង “សេចក្តីថ្លែងការណ៍ក្នុងចេតនាប្រព្រឹត្តអំពើហិង្សា។ បន្ទាប់ពីអ្នកប្រើប្រាស់ដែលបានរាយការណ៍អំពីខ្លឹមសារបានប្តឹងជំទាស់មក ខ្លឹមសារនោះត្រូវបានពិនិត្យមើលដោយអ្នកពិនិត្យមើលជាមនុស្សពីរនាក់ដែលបានរកឃើញថាខ្លឹមសារនោះមិនបំពានគោលការណ៍របស់ Meta ទេ។ ក្នុងពេលជាមួយគ្នានេះ ខ្លឹមសារត្រូវបានបញ្ជូនបន្តទៅអ្នកជំនាញផ្នែកគោលការណ៍ និងសាច់រឿងនៃវិវាទនៅក្នុង Meta។ ពួកគាត់បានសម្រេចថាខ្លឹមសារនោះបានបំពានលើស្តង់ដារសហគមន៍ស្តីពីអំពើហិង្សា និងការញុះញង់ ប៉ុន្តែបានអនុវត្តការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាន។ បើមិនដូច្នេះទេ ករណីនេះអនុញ្ញាតឱ្យមានខ្លឹមសារដែលបំពាន ដែលគុណតម្លៃផលប្រយោជន៍សាធារណៈមានកម្រិតលើសពីហានិភ័យដែលវាបង្កគ្រោះថ្នាក់។

អ្នកប្រើប្រាស់ម្នាក់ក្នុងចំណោមអ្នកប្រើប្រាស់ដែលបានរាយការណ៍ខ្លឹមសារបានប្តឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់ Meta ទៅកាន់ក្រុមប្រឹក្សាភិបាល។ ដោយឡែក Meta បានបញ្ជូនសំណុំរឿងនេះទៅដល់ក្រុមប្រឹក្សាភិបាល។ នៅក្នុងការបញ្ជូនបន្តនៃសំណុំរឿងនោះ Meta បានបញ្ជាក់ថាសំណុំរឿងនេះពាក់ព័ន្ធនឹងតុល្យភាពដ៏លំបាករវាងគុណតម្លៃរបស់ខ្លឹមសារនៃ “សុវត្ថិភាព” និង “សិទ្ធិបញ្ចេញមតិ” ក្នុងការសម្រេចថាតើពេលណាត្រូវអនុញ្ញាតឱ្យបន្តមានសុន្ទរកថាដែលបំពានលើគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់ដោយមេដឹកនាំនយោបាយនៅលើវេទិការបស់ខ្លួន។

## លទ្ធផលរកឃើញសំខាន់ៗ

ក្រុមប្រឹក្សាភិបាលយល់ឃើញថា វីដេអូក្នុងសំណុំរឿងនេះ បានរួមបញ្ចូលសេចក្តីថ្លែងការណ៍ច្បាស់លាស់ក្នុងចេតនាប្រព្រឹត្តអំពើហិង្សាលើគូប្រជែងនយោបាយរបស់លោក ហ៊ុន សែន ដែលបំពានលើគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់យ៉ាងច្បាស់។ ការប្រើប្រាស់ពាក្យពេចន៍ដូចជា “ដំបង” និង “ការបញ្ជូនក្មេងទំនើងទៅផ្ទះ [របស់អ្នក]” ឬ “ចំណាត់ការផ្លូវច្បាប់” រួមទាំងការចាប់ខ្លួនពាក់កណ្តាលអធ្រាត្រ ស្មើនឹងការញុះញង់ឱ្យមានអំពើហិង្សា និងការគំរាមកំហែងផ្នែកច្បាប់។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា Meta ប្រព្រឹត្តខុសក្នុងការអនុវត្តការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មានក្នុងករណីនេះ ដោយសារគ្រោះថ្នាក់ដែលបណ្តាលមកពីការអនុញ្ញាតឱ្យមានខ្លឹមសារនៅលើវេទិកាគឺលើសពីគុណតម្លៃផលប្រយោជន៍សាធារណៈរបស់សារបង្ហោះ។ ដោយសារតែការផ្សព្វផ្សាយរបស់លោក ហ៊ុន សែន នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលអនុញ្ញាតឱ្យមានការបញ្ចេញមតិបែបនេះនៅលើ Facebook ផ្តល់លទ្ធភាពឱ្យការគំរាមកំហែងរបស់គាត់រីករាលដាលកាន់តែទូលំទូលាយ។ វាក៏បណ្តាលឱ្យវេទិការបស់ Meta

រួមចំណែកដល់គ្រោះថ្នាក់ទាំងនេះតាមរយៈការផ្សព្វផ្សាយការគំរាមកំហែង និងការបំភិតបំភ័យជាលទ្ធផលផងដែរ។

ក្រុមប្រឹក្សាភិបាលក៏មានការព្រួយបារម្ភផងដែរថា យុទ្ធនាការបៀតបៀន និងការបំភិតបំភ័យជាបន្តបន្ទាប់របស់មេដឹកនាំនយោបាយប្រឆាំងនឹងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងបក្សពួកប្រឆាំងនយោបាយអាចក្លាយជាកត្តាមួយក្នុងការវាយតម្លៃភាពស័ក្តិសមជាព័ត៌មានដែលនាំឱ្យខ្លឹមសារដែលបំពានមិនត្រូវបានដកចេញ និងគណនីមិនទទួលរងការដាក់ទោសពិន័យ។ ឥរិយាបថបែបនេះមិនគួរលើកទឹកចិត្តឱ្យមាននោះទេ។ Meta គួរតែថ្លឹងថ្លែងឱ្យកាន់តែធ្ងន់ទៅលើសេរីភាពសារព័ត៌មាន នៅពេលពិចារណាអំពីភាពស័ក្តិសមជាព័ត៌មាន ដើម្បីកុំឱ្យមានការអត់ឱនចំពោះសុន្ទរកថារបស់រដ្ឋាភិបាលក្នុងស្ថានភាពដែលរដ្ឋាភិបាលនោះបានបង្កើតខ្លឹមសារផ្ទាល់របស់ខ្លួនឱ្យកាន់តែមានតម្លៃជាព័ត៌មានដោយការដាក់កំណត់សេរីភាពសារព័ត៌មាន។

ក្រុមប្រឹក្សាភិបាលជំរុញឱ្យ Meta បញ្ជាក់ឱ្យច្បាស់ថា គោលការណ៍របស់ខ្លួនស្តីពីការរឹតបន្តឹងគណនីរបស់បុគ្គលសាធារណៈមិនត្រូវបានកំណត់ត្រឹមតែឧប្បត្តិហេតុនៃអំពើហិង្សា និងចលាចលស៊ីវិលតែមួយប៉ុណ្ណោះនោះទេ ប៉ុន្តែក៏អនុវត្តចំពោះបរិបទដែលប្រជាពលរដ្ឋស្ថិតនៅក្រោមការគំរាមកំហែងបន្តបន្ទាប់ពីអំពើហិង្សាសងសឹកពីរដ្ឋាភិបាលរបស់ពួកគេ។

ក្នុងករណីនេះ ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃការរំលោភបំពាននេះ ប្រវត្តិរបស់លោក ហ៊ុន សែន ធ្លាប់ប្រព្រឹត្តការរំលោភបំពានសិទ្ធិមនុស្ស និងការបំភិតបំភ័យគូប្រជែងនយោបាយ ក៏ដូចជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមជាយុទ្ធសាស្ត្រដើម្បីផ្សព្វផ្សាយការគំរាមកំហែងបែបនេះ ក្រុមប្រឹក្សាភិបាលសូមអំពាវនាវ Meta ឱ្យផ្អាកជាបន្ទាន់នូវទំព័រ Facebook និងគណនី Instagram របស់លោក ហ៊ុន សែនរយៈពេលប្រាំមួយខែ។

## សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យ

ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យបដិសេធសេក្តីសម្រេចរបស់ Meta ក្នុងការបន្តឱ្យមានខ្លឹមសារនេះ ដោយតម្រូវឱ្យដកសារបង្ហោះនោះចេញ។

ក្រុមប្រឹក្សាភិបាលបានណែនាំឱ្យ Meta៖

- ផ្អាកជាបន្ទាន់នូវទំព័រ Facebook និងគណនី Instagram ផ្លូវការរបស់នាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន ក្នុងរយៈពេលប្រាំមួយខែ

ក្រោមគោលការណ៍របស់ Meta ស្ដីពីការរឹតបន្តឹងគណនីរបស់បុគ្គលសាធារណៈអំឡុងពេលមានចលាចលស៊ីវិល។ ក្រុមប្រឹក្សាភិបាលនឹងចាត់ទុកអនុសាសន៍នេះត្រូវបានអនុវត្ត នៅពេលដែល Meta ផ្អាកគណនី និងប្រកាសជាសាធារណៈថាខ្លួនបានធ្វើដូច្នេះ។

- បញ្ជាក់ឱ្យច្បាស់ថា គោលការណ៍របស់ខ្លួនសម្រាប់រឹតបន្តឹងគណនីរបស់បុគ្គលសាធារណៈអនុវត្តចំពោះបរិបទដែលប្រជាពលរដ្ឋស្ថិតនៅក្រោមការគំរាមកំហែងជាបន្តបន្ទាប់ពីអំពើហិង្សាសងសឹកពីរដ្ឋាភិបាលរបស់ពួកគេ។ គោលការណ៍នេះគួរតែបញ្ជាក់ឱ្យច្បាស់ថា គោលការណ៍នេះមិនត្រូវបានរឹតបន្តឹងត្រឹមតែឧបទ្ទវហេតុតែមួយនៃភាពចលាចលស៊ីវិល ឬអំពើហិង្សាប៉ុណ្ណោះទេ ហើយថាគោលការណ៍នេះត្រូវបានអនុវត្ត ក្នុងករណីដែលការបញ្ចេញមតិនយោបាយត្រូវបានគាបសង្កត់ជាមុន ឬឆ្លើយតបដោយអំពើហិង្សា ឬការគំរាមកំហែងនៃអំពើហិង្សាពីរដ្ឋ។

- ធ្វើបច្ចុប្បន្នភាពគោលការណ៍ស្ដីពីការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មានរបស់ខ្លួន ដើម្បីបញ្ជាក់ថាខ្លឹមសារដែលញុះញង់ឱ្យមានអំពើហិង្សាដោយផ្ទាល់គឺមិនមានសិទ្ធិទទួលបានការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាននោះទេ ដែលអាចនឹងមានការលើកលែងពីគោលការណ៍ដែលមានស្រាប់។

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធកំណត់អាទិភាពនៃការពិនិត្យមើលរបស់ខ្លួន ដើម្បីធានាថាខ្លឹមសារពីប្រមុខរដ្ឋ និងសមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាលសក្តានុពលដែលបានបំពានលើគោលការណ៍ស្ដីពីអំពើហិង្សា និងការញុះញង់ត្រូវបានផ្ដល់អាទិភាពជាប់លាប់សម្រាប់ការពិនិត្យមើលភ្លាមៗដោយមនុស្ស។

- អនុវត្តការផ្លាស់ប្ដូរគោលការណ៍ណែនាំផលិតផល និង/ឬគោលការណ៍ណែនាំប្រតិបត្តិការដែលអនុញ្ញាតឱ្យមានការពិនិត្យមើលត្រឹមត្រូវជាងមុនលើវីដេអូទម្រង់វែង (ឧ. ការប្រើក្បួនដោះស្រាយសម្រាប់ព្យាកររយៈពេលនៃការបំពាន ដែលធានាបាននូវពេលវេលាពិនិត្យមើលសមស្របជាមួយនឹងរយៈពេលវីដេអូ ដែលអនុញ្ញាតឱ្យវីដេអូចាក់ ១,៥x ឬលឿនជាង ២x ។ល។)

- បង្ហាញជាសាធារណៈអំពីវិសាលភាពនៃចំណាត់ការ និងហេតុផលនៅពីក្រោយសេចក្ដីសម្រេចរបស់ខ្លួនចំពោះករណីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគ្រប់ចំណាត់ការកម្រិតគណនីប្រឆាំងនឹងប្រមុខរដ្ឋ និងសមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាល។

* សេចក្តីសង្ខេបនៃសំណុំរឿងផ្តល់នូវទិដ្ឋភាពទូទៅអំពីសំណុំរឿង និងមិនមានតម្លៃពីមុនទេ។

## សេចក្តីសម្រេចលើសំណុំរឿងពេញលេញ

### 1. សេចក្តីសង្ខេបអំពីសេចក្តីសម្រេច

ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យបដិសេធសេចក្តីសម្រេចរបស់ Meta ក្នុងការបន្តរក្សាទុកវីដេអូនៅលើ Facebook ដោយផ្តល់ការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាន ដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គំរាមគូប្រជែងនយោបាយរបស់គាត់ដោយហិង្សា។

Meta បានបញ្ជូនសំណុំរឿងនេះទៅក្រុមប្រឹក្សាភិបាល ដោយសារករណីនេះមានបញ្ហាពិបាកៗទាក់ទងនឹងតុល្យភាពរវាងតម្រូវការក្នុងការអនុញ្ញាតឱ្យអ្នកប្រើប្រាស់បានស្តាប់ឮពីមេដឹកនាំនយោបាយរបស់ពួកគេ និងតម្រូវការដើម្បីរារាំងមេដឹកនាំទាំងនោះពីការប្រើប្រាស់វេទិកាក្នុងការគំរាមកំហែងគូប្រជែងរបស់ពួកគេដោយអំពើហិង្សា ឬបំភិតបំភ័យអ្នកដទៃមិនឱ្យចូលរួមក្នុងសកម្មភាពនយោបាយ។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ការលើកឡើងរបស់លោក ហ៊ុន សែន បានបំពានស្តង់ដារសហគមន៍ស្តីពីអំពើហិង្សា និងការញុះញង់។ ហើយក៏យល់ឃើញផងដែរថាសេចក្តីសម្រេចរបស់ Meta ដែលថាខ្លឹមសារមានភាពស័ក្តិសមជាព័ត៌មានគ្រប់គ្រាន់ដើម្បីរក្សាទុកនៅលើវេទិកា ទោះបីជាមានការបំពានក៏ដោយ គឺជារឿងមិនត្រឹមត្រូវ។ ក្រុមប្រឹក្សាភិបាលសន្និដ្ឋានថាខ្លឹមសារគួរតែត្រូវបានដកចេញពីវេទិកា។ ជាងនេះទៅទៀត ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃការរំលោភបំពាន បរិបទនយោបាយនៅកម្ពុជា ប្រវត្តិរបស់រដ្ឋាភិបាលធ្លាប់បំពានលើសិទ្ធិមនុស្ស ប្រវត្តិរបស់លោក ហ៊ុន សែន ក្នុងការញុះញង់ឱ្យមានអំពើហិង្សាលើគូប្រជែងរបស់លោក និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមជាយុទ្ធសាស្ត្រដើម្បីផ្សព្វផ្សាយការគំរាមកំហែងបែបនេះ ក្រុមប្រឹក្សាភិបាលមានជំនឿថា Meta គួរផ្អាកជាបន្ទាន់នូវទំព័រ Facebook និងគណនី Instagram ផ្លូវការរបស់លោក ហ៊ុន សែន រយៈពេលប្រាំមួយខែ។

## 2. ការពណ៌នា និងប្រវត្តិសាវតារនៃសំណុំរឿង

កាលពីថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២៣ វីដេអូផ្សាយផ្ទាល់មួយត្រូវបានផ្សាយនៅលើទំព័រ Facebook ផ្លូវការរបស់នាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន។ វីដេអូនេះបង្ហាញពីសុន្ទរកថារយៈពេលមួយម៉ោង ៤១ នាទី ដែលលោក ហ៊ុន សែន ថ្លែងជាភាសាខ្មែរ ដែលជាភាសាផ្លូវការរបស់កម្ពុជា ក្នុងពិធីអបអរសាទរបើកគម្រោងពង្រីកផ្លូវជាតិក្នុងខេត្តកំពង់ចាម។ ក្នុងសុន្ទរកថានោះ គាត់ឆ្លើយតបនឹងការចោទប្រកាន់ថា គណបក្សប្រជាជនកម្ពុជា (CPP) ដែលកំពុងកាន់អំណាចបានលួចសន្លឹកឆ្នោតក្នុងអំឡុងពេលបោះឆ្នោតមូលដ្ឋានក្នុងប្រទេសនៅឆ្នាំ ២០២២។ គាត់អំពាវនាវឱ្យគូប្រជែងនយោបាយរបស់គាត់ដែលបានធ្វើការចោទប្រកាន់នោះជ្រើសរើសរវាង "ប្រព័ន្ធផ្លូវច្បាប់" និង "ដំបង" និងនិយាយថាពួកគាត់អាចជ្រើសរើសប្រព័ន្ធច្បាប់ ឬក៏គាត់ "នឹងប្រមូលផ្តុំមនុស្សរបស់គណបក្សប្រជាជនកម្ពុជាដើម្បីតវ៉ា និងវាយទាត់ជាក់អ្នក"។ គាត់បន្ថែមទៀតថា "ប្រសិនបើអ្នកនិយាយថានោះជាសេរីភាពនៃការបញ្ចេញមតិ ខ្ញុំក៏នឹងបង្ហាញពីសេរីភាពរបស់ខ្ញុំផងដែរ ដោយបញ្ជូនមនុស្សទៅកន្លែង និងផ្ទះរបស់អ្នក" និងលើកឡើងថានឹងបញ្ជូន "ក្រុមក្មេងទំនើងទៅផ្ទះ [របស់អ្នក]"។ គាត់ហៅឈ្មោះបុគ្គលនោះដោយព្រមានថាពួកគាត់ "ត្រូវតែមានឥរិយាបថគួរសម" ហើយនិយាយថាគាត់អាចនឹង "ចាប់ខ្លួនជនក្បត់ដោយមានភស្តុតាងគ្រប់គ្រាន់នៅពាក់កណ្ដាលអធ្រាត្រ"។ ទោះយ៉ាងណាក៏ដោយ ប្រហែល ២២ នាទីក្រោយមកនៅក្នុងសុន្ទរកថា គាត់លើកឡើងថា "យើងមិនញុះញង់ប្រជាពលរដ្ឋ និងលើកទឹកចិត្តប្រជាជនឱ្យប្រើកម្លាំង" នោះទេ។ បន្ទាប់ពីការផ្សាយផ្ទាល់ វីដេអូនេះត្រូវបានបង្ហោះដោយស្វ័យប្រវត្តិទៅលើទំព័រ Facebook របស់លោក ហ៊ុន សែន ដែលមានអ្នកតាមដានប្រមាណ ១៤ លាននាក់ ដែលមានអ្នកចូលមើលប្រមាណ ៦០០.០០០ ដង។ វីដេអូនេះត្រូវបានចែករំលែកដោយមនុស្សជិត ៣.០០០ នាក់ផ្សេងទៀតជិត ៤.០០០ ដង។

អ្នកប្រើប្រាស់បីនាក់បានរាយការណ៍វីដេអូនេះប្រាំដងនៅចន្លោះថ្ងៃទី ៩ ខែមករា ដល់ថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០២៣ សម្រាប់ការបំពានលើស្តង់ដារសហគមន៍ស្តីពីអំពើហិង្សា និងការញុះញង់របស់ Meta។ គោលការណ៍នេះហាមឃាត់ "ការគំរាមកំហែងដែលអាចបណ្ដាលឱ្យមានការស្លាប់" (អំពើហិង្សាកម្រិតធ្ងន់ធ្ងរ) និង "ការគំរាមកំហែងដែលនាំឱ្យមានរបួសធ្ងន់ធ្ងរ (អំពើហិង្សាពាក់កណ្ដាលធ្ងន់ធ្ងរ)" រួមទាំង "សេចក្តីថ្លែងការណ៍ក្នុងចេតនាប្រព្រឹត្តអំពើហិង្សា"។ ជាទូទៅ Meta កំណត់អាទិភាពលើខ្លឹមសារសម្រាប់ការពិនិត្យមើលដោយមនុស្សដោយផ្អែកលើភាពធ្ងន់ធ្ងរ ភាពផ្ទុះល្បី និងលទ្ធភាពនៃគោលការណ៍ស្តីពីខ្លឹមសារដែលបំពាន។ ក្នុងករណីនេះ ប្រព័ន្ធស្វ័យប្រវត្តិរបស់ Meta មិនបានកំណត់អាទិភាពខ្លឹមសារនោះទេ និងមិនបានបិទរបាយការណ៍របស់អ្នកប្រើប្រាស់ដោយគ្មានការពិនិត្យមើលដោយមនុស្សទេ។ បន្ទាប់ពីអ្នកប្រើប្រាស់ដែលបានរាយការណ៍អំពីខ្លឹមសារបានប្តឹងជំទាស់ អ្នកពិនិត្យមើលជាមនុស្សពីរនាក់បានរកឃើញថាខ្លឹមសារនោះមិនបំពានគោលការណ៍របស់

Meta ទេ។ ក្នុងពេលជាមួយគ្នានេះ ខ្លឹមសារត្រូវបានបញ្ជូនបន្តទៅអ្នកជំនាញផ្នែកគោលការណ៍ និងសាច់រឿងនៃវិវាទនៅក្នុង Meta។ នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២៣ អ្នកជំនាញផ្នែកគោលការណ៍ និងសាច់រឿងនៃវិវាទទាំងនោះបានសម្រេចថាវីដេអូនោះបានបំពានលើស្តង់ដារសហគមន៍ស្តីពីអំពើហិង្សា និងការញុះញង់ ប៉ុន្តែបានអនុវត្តការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាន ដើម្បីបន្តរក្សាទុកវីដេអូនោះនៅលើវេទិកា។ បើមិនដូច្នេះទេ ការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មានអនុញ្ញាតឱ្យបន្តរក្សាទុកខ្លឹមសារដែលបំពានផ្សេងទៀត នៅលើវេទិការបស់ Meta ដែលគុណតម្លៃផលប្រយោជន៍សាធារណៈរបស់ខ្លឹមសារនោះមានកម្រិតលើសពីហានិភ័យដែលខ្លឹមសារនោះបង្កគ្រោះថ្នាក់។ អ្នកប្រើប្រាស់ម្នាក់ដែលបានរាយការណ៍អំពីខ្លឹមសារបានប្ដឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់ Meta ទៅកាន់ក្រុមប្រឹក្សាភិបាល។ ដោយឡែក Meta បានបញ្ជូនសំណុំរឿងនេះទៅដល់ក្រុមប្រឹក្សាភិបាល។

បរិបទនយោបាយ និងសង្គមនៅប្រទេសកម្ពុជាគឺពាក់ព័ន្ធជាពិសេសទៅនឹងការវាយតម្លៃខ្លឹមសារក្នុងសំណុំរឿងនេះ។ លោក ហ៊ុន សែន ដែលបច្ចុប្បន្នមានអាយុ ៧០ ឆ្នាំ ជាអតីតមេបញ្ជាការខ្មែរក្រហម និងបានកាន់អំណាចតាំងពីឆ្នាំ ១៩៨៥។ បច្ចុប្បន្នគាត់កំពុងឈរឈ្មោះបោះឆ្នោតឡើងវិញ ដោយការបោះឆ្នោតទូទៅរបស់ប្រទេសកម្ពុជានឹងធ្វើឡើងនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០២៣ ទោះបីជាមានការរាយការណ៍ ថាលោកអាចនឹងប្រគល់អំណាចទៅកូនប្រុសរបស់គាត់ក៏ដោយ។ អ្នករិះគន់រដ្ឋាភិបាលរបស់គាត់បានប្រឈមមុខនឹងអំពើហិង្សានយោបាយដែលបានកំណត់គោលដៅជាយូរមកហើយ ដោយមានសកម្មជនប្រឆាំងជាង ៣០ នាក់រងការវាយប្រហារចន្លោះឆ្នាំ ២០១៧ និង ២០២២។ សមាជិកបក្សប្រឆាំង និងសកម្មជននយោបាយត្រូវបានសម្លាប់ក្រោមកាលៈទេសៈដ៏គួរឱ្យសង្ស័យ ដូចជាការសម្លាប់អ្នកអត្ថាធិប្បាយនយោបាយដ៏លេចធ្លោគឺលោក កែម ឡី ក្នុងឆ្នាំ ២០១៦ ជាដើម។

កាលពីឆ្នាំ ២០១៥ លោក ហ៊ុន សែន បានព្រមានអំពីការវាយប្រហារប្រឆាំងនឹងគណបក្សសង្គ្រោះជាតិ (CNRP) ដែលជាគណបក្សប្រឆាំងនឹងគាត់ ប្រសិនបើអ្នកណាម្នាក់តវ៉ាចំពោះដំណើរទស្សនកិច្ចការទូតរបស់គាត់ទៅកាន់ប្រទេសបារាំង។ ភ្លាមៗបន្ទាប់ពីបានផ្ទុះការតវ៉ា សមាជិកសភាបក្សប្រឆាំងពីរនាក់ត្រូវបានហ្វូងមនុស្សវាយដំ និងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដោយមានរបួសធ្ងន់ធ្ងរ។ ក្នុងខែវិច្ឆិកា ឆ្នាំ ២០២១ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានសម្តែងការព្រួយបារម្ភជុំវិញការសម្លាប់សមាជិកគណបក្សសង្គ្រោះជាតិ ដែលបានទទួលការគំរាមកំហែងជាច្រើនខែមុន។ ការវាយប្រហារនេះបានកើតឡើងប៉ុន្មានសប្តាហ៍បន្ទាប់ពីលោក ហ៊ុន សែន បានគំរាមកំហែងថា “នឹងធ្វើអ្វីដែលខ្លួនត្រូវការដើម្បីបង្ក្រាប [លើ]

ការតវ៉ាក្នុងអំឡុងពេលធ្វើជាប្រធានអាស៊ានរបស់កម្ពុជា”។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមួយនៅក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា ចន្លោះឆ្នាំ ២០១៧ និង ២០២២ សកម្មជនបក្សប្រឆាំងជាង ៣០ នាក់ត្រូវបាន “វាយប្រហារដោយហិង្សា” ជាធម្មតាដោយ “ជនមិនស្គាល់មុខតាមដងផ្លូវសាធារណៈ”។ នៅក្នុងអត្ថាធិប្បាយសាធារណៈ (PC-១១០៨៤) គម្រោងសុន្ទរកថាដែលមានគ្រោះថ្នាក់បានព្រមានថា ភាសាអុជអាលរបស់លោក ហ៊ុន សែន បង្កើនឆន្ទៈរបស់អ្នកទទួលរបស់គាត់ក្នុងការប្រព្រឹត្ត និងអត់ទោសអំពើហិង្សាលើគូប្រជែងរបស់គាត់។ ការព្យាករនោះត្រូវបានបញ្ជាក់នាពេលថ្មីៗនេះជាមួយនឹងអង្គការឃ្លាំមើលសិទ្ធិមនុស្សដោយភ្ជាប់អំពើហិង្សាជាច្រើនប្រឆាំងនឹងសមាជិកគណបក្សប្រឆាំងដោយផ្ទាល់ទៅក្នុងសុន្ទរកថាដ៏សំខាន់បំផុតកាលពីថ្ងៃទី ៩ ខែមករានៅក្នុងករណីនេះ។ ក្រុមប្រឹក្សាភិបាលសូមថ្លែងអំណរគុណចំពោះភាគីពាក់ព័ន្ធ និងអ្នកអត្ថាធិប្បាយជាសាធារណៈសម្រាប់ការគូសបញ្ជាក់ពីកម្រិត និងភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តបំពានសិទ្ធិមនុស្ស ឬមានការអត់ឱនពីរដ្ឋាភិបាលកម្ពុជា។

អ្នកជំនាញឯករាជ្យដែលត្រូវបានពិគ្រោះយោបល់ដោយក្រុមប្រឹក្សាភិបាលរាយការណ៍ថា ក្នុងរយៈពេល ១២ ខែចុងក្រោយនេះ លោក ហ៊ុន សែន បានប្រើ Facebook និង Instagram ដើម្បីបង្ហាញការគំរាមកំហែងដោយបង្កប់ន័យជាច្រើនទៅលើគូប្រជែងនយោបាយរបស់គាត់។ ថ្មីៗនេះ គាត់បានបង្ហោះនូវអ្វីដែលហាក់ដូចជាការគំរាមកំហែងដល់ប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេស ដោយព្រមានមិនឱ្យពួកគាត់ “ប្រឆាំងនឹងការបោះឆ្នោត”។ កាលពីខែឧសភា ឆ្នាំ ២០១៧ មិនយូរប៉ុន្មានមុនការបោះឆ្នោតមូលដ្ឋាន លោក ហ៊ុន សែន ថ្លែងនៅក្នុងសុន្ទរកថាដែលចាក់ផ្សាយតាម Facebook ថាគាត់ “សុខចិត្តលុបបំបាត់មនុស្សពី ១០០ ឬ ២០០ នាក់” ប្រសិនបើចាំបាច់ដើម្បីធានាសន្តិភាពក្នុងប្រទេស និងគំរាមកំហែងថានឹងមានសង្គ្រាមស៊ីវិល ប្រសិនបើគាត់បានបាត់បង់អំណាច ដែលជាការគំរាមកំហែងដែលគាត់បានធ្វើឡើងជាច្រើនដងក្នុងអាណត្តិរបស់គាត់ជានាយករដ្ឋមន្ត្រី។ បន្តិចក្រោយមកនៅក្នុងសុន្ទរកថាមួយផ្សេងទៀត ដែលក្រុមប្រឹក្សាភិបាលមិនអាចបញ្ជាក់បានទេថាតើគាត់បានបង្ហោះនៅលើវេទិការបស់ Meta ឬអត់នោះទេ ដោយគាត់បានព្រមានថាអ្នករិះគន់ និងគូប្រជែងនយោបាយគួរតែ “រៀបចំមឈូសរបស់ពួកគាត់” ប្រសិនបើពួកគាត់បន្ត ចោទគាត់ពីបទគំរាមកំហែងសង្គ្រាមស៊ីវិល ប្រសិនបើគាត់ចាញ់ការបោះឆ្នោត។ លោក ហ៊ុន សែន ក៏បានអះអាងដែរថា គាត់សោកស្ដាយដែលមិនបានសម្លាប់មេដឹកនាំគណបក្សប្រឆាំង ដែលបានរៀបចំការតវ៉ាទាមទារឱ្យគាត់លាលែងពីតំណែងក្រោយការបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២០១៣។ បន្ទាប់ពីក្រុមប្រឹក្សាភិបាលបានជ្រើសរើសសំណុំរឿងនេះ នៅក្នុងសុន្ទរកថាដែលផ្សាយផ្ទាល់នៅលើ Facebook លោក ហ៊ុន សែន បានគំរាមបាញ់មេដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី ដោយគ្រាប់រ៉ុក្កែត។

ជ័យជម្នះការបោះឆ្នោតចុងក្រោយបំផុតរបស់លោក ហ៊ុន សែន បានកើតឡើងក្នុងឆ្នាំ ២០១៨ នៅពេលដែលគណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈទាំង ១២៥ នៅក្នុងរដ្ឋសភា។ មុនការបោះឆ្នោតទាំងនោះ តុលាការកំពូលកម្ពុជា បានសម្រេចរំលាយគណបក្សប្រឆាំងសង្គ្រោះជាតិ (CNRP) ហើយមន្ត្រីជាន់ខ្ពស់របស់គណបក្សនោះចំនួន ១១៨ នាក់ ត្រូវបានហាមឃាត់មិនឱ្យធ្វើនយោបាយរយៈពេលប្រាំឆ្នាំ។ ការហាមឃាត់ និងចំណាត់ការផ្លូវច្បាប់ដែលពាក់ព័ន្ធបានធ្វើតាមការគំរាមកំហែង និងសេចក្តីបង្គាប់ជាសាធារណៈយ៉ាងឆាប់រហ័សពីលោក ហ៊ុន សែន ផ្ទាល់។ នៅក្នុងរបាយការណ៍ឆ្នាំ ២០១៧ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបានកត់សម្គាល់ឃើញថាមេដឹកនាំគណបក្សប្រឆាំងជាច្រើននាក់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្ម រួមទាំងសមាជិកព្រឹទ្ធសភាពីរនាក់ដែលត្រូវបានកាត់ទោសដោយផ្អែកលើសារបង្ហោះលើ Facebook។

នៅមុនការបោះឆ្នោតឆ្នាំ ២០២៣ រដ្ឋាភិបាលលោក ហ៊ុន សែន បានដាក់សម្ពាធកាន់តែខ្លាំងទៅលើសមាជិកគណបក្សប្រឆាំង ស្ថាប័នសារព័ត៌មានឯករាជ្យ និងក្រុមសង្គមស៊ីវិល ដោយប្រើការកាត់ទោសដោយហេតុផលនយោបាយ និងទម្រង់ផ្សេងទៀតនៃការបំភិតបំភ័យ។ នៅក្នុងអត្ថាធិប្បាយសាធារណៈ គណៈកម្មាធិការអន្តរជាតិនៃអ្នកច្បាប់និតិបុគ្គល (ICJ) (PC-១១០៣៨) បានកត់សម្គាល់ឃើញថា លោក ហ៊ុន សែន និងអាជ្ញាធរកម្ពុជា “បានរឹតបន្តឹងសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានជាប្រព័ន្ធ” តាមរយៈចំណាត់ការនានាដូចជាការផ្តន្ទាទោសច្រើនរបស់មេដឹកនាំគណបក្សប្រឆាំងលើបទចោទប្រកាន់មិនពិត និងជាញឹកញាប់*មិនមានវត្តមាន*។ ICJ ក៏បានលើកឡើងពីការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរចំពោះ “ការប្រើប្រាស់ច្បាប់ជាអាវុធដែលផ្ទុយនឹងច្បាប់ និងស្តង់ដារសិទ្ធិមនុស្ស”។ របាយការណ៍ឆ្នាំ ២០២២ របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានកត់សម្គាល់ឃើញថាឯករាជ្យភាព និងតម្លាភាពនៃប្រព័ន្ធតុលាការគឺជា “បញ្ហាដែលកើតមានយូរមកហើយ” ប៉ុន្តែមាន “ការផ្លាស់ប្តូរថ្មីៗជាងនេះ . . . ក្នុងនោះមន្ត្រីតុលាការ និងមន្ត្រីពាក់ព័ន្ធមួយចំនួនមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សនយោបាយដែលកាន់អំណាច”។ ក្រៅពីប្រព័ន្ធតុលាការ របាយការណ៍ដដែលនេះក៏បានរកឃើញកម្រិតនៃឥទ្ធិពលមិនសមរម្យលើប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធបោះឆ្នោតផងដែរ។ ទាក់ទងនឹងការបោះឆ្នោតមូលដ្ឋានដែលធ្វើឡើងក្នុងខែមិថុនា ឆ្នាំ ២០២២ អ្នករាយការណ៍ពិសេសបានចោទសួរថា តើសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានទំនាក់ទំនងជិតស្និទ្ធខ្លាំងយ៉ាងណាជាមួយគណបក្សកាន់អំណាច និងបានចងក្រងឯកសារស្តីពីការលុបឈ្មោះបេក្ខជន “ចំនួនច្រើន” មុនការបោះឆ្នោត ជាពិសេស គណបក្សភ្លើងទៀន ដែលជាគណបក្សប្រឆាំងដ៏សំខាន់

ដែលស្ថិតក្រោមកាលៈទេសៈគួរឱ្យសង្ស័យ។ នៅចុងឆ្នាំ ២០២២ លោក ហ៊ុន សែន បានគំរាមថានឹងប្រើប្រាស់តុលាការថ្នាក់ជាតិម្តងទៀត ដើម្បីរំលាយបក្សពួកប្រឆាំងចម្បងរបស់គាត់មុនការបោះឆ្នោតឆ្នាំ ២០២៣។ បន្តិចក្រោយមកទៀត ក្នុងខែឧសភា ឆ្នាំ ២០២៣ គ.ជ.ប បានបដិសេធមិនចុះឈ្មោះគណបក្សភ្លើងទៀន ដោយបានដកសិទ្ធិពីការបោះឆ្នោតខែកក្កដា និងដកចេញនូវបញ្ហាប្រឈមដ៏គួរឱ្យទុកចិត្តតែមួយគត់របស់លោក ហ៊ុន សែន។ បន្ទាប់ពីសេចក្តីសម្រេចនេះត្រូវបានធ្វើឡើង តាមរយៈសារបង្ហោះលើ Facebook លោក ហ៊ុន សែន បានគំរាមកំហែងថាអ្នកណាម្នាក់ដែលតវ៉ាប្រឆាំងនឹងការដកសិទ្ធិបោះឆ្នោតនេះនឹងមាន "ការចាប់ខ្លួន និងទទួលរងវិធានការផ្លូវច្បាប់"។ ពេលពិភាក្សាអំពីការគំរាមកំហែងរបស់គាត់ក្នុងការបង្ក្រាបការតវ៉ា ក្រោយមកគាត់បានបញ្ជាក់ថា "ពេលលោក ហ៊ុន សែន និយាយ គឺគាត់ធ្វើ"។

រដ្ឋាភិបាលលោក ហ៊ុន សែន ក៏បានរារាំងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យផងដែរ ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបញ្ជាក់ថា ស្ទើរតែគ្មានស្ថាប័នប្រព័ន្ធផ្សព្វផ្សាយសេរីណាដែលដំណើរការក្នុងប្រទេស" នៅមុនការបោះឆ្នោតខែកក្កដានោះទេ។ យោងតាមអ្នកជំនាញដែលសុំមិនបញ្ចេញឈ្មោះ ការរួមបញ្ចូលគ្នានៃការបិទប្រព័ន្ធផ្សព្វផ្សាយទាំងនេះ ការប្រើប្រាស់ប្រព័ន្ធតុលាការរបស់កម្ពុជាជាអាវុធប្រឆាំងនឹងគូប្រជែង និងអំពើហិង្សានយោបាយដែលបានកំណត់គោលដៅបានបង្កឱ្យមាន "បរិយាកាសបណ្តុះឱ្យមានភ័យខ្លាចដោយចេតនា"។ សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជាបានកត់ត្រា សំណុំរឿងបៀតបៀនអ្នកសារព័ត៌មានចំនួន ៣៥ ករណីក្នុងឆ្នាំ ២០២២។ យោងតាមអត្ថាធិប្បាយសាធារណៈ និងអ្នកជំនាញ វប្បធម៌នៃការបំភិតបំភ័យនេះបានធ្វើឱ្យមានផលប៉ះពាល់ដល់ការរាយការណ៍សុក្រិតយ៉ាងខ្លាំង ដោយស្ថាប័នប្រព័ន្ធផ្សព្វផ្សាយមានការស្ទាក់ស្ទើរក្នុងការបិទបាំងបញ្ហារសើប ឬសុន្ទរកថាដ៏ចម្រូងចម្រាសដោយលោក ហ៊ុន សែន ព្រោះខ្លាចរដ្ឋាភិបាលសងសឹក។ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយទាំងនេះក៏ទទួលរងការបំភិតបំភ័យក្នុងការផលិតឡើងវិញនូវការឃោសនារបស់រដ្ឋាភិបាលដោយគ្មានអត្ថាធិប្បាយរិះគន់ផងដែរ។

បន្ទាប់ពីទទួលបានជ័យជម្នះដ៏តឹងតែងនៅក្នុងការបោះឆ្នោតទូទៅឆ្នាំ ២០១៣ រដ្ឋាភិបាលរបស់លោក ហ៊ុន សែន បានទទួលស្គាល់អំណាចនៃប្រព័ន្ធផ្សព្វផ្សាយសង្គម និងបានពង្រឹងនិន្នាការរបស់ប្រទេសកម្ពុជាឆ្ពោះទៅរកអ្វីដែល Freedom House បានពណ៌នាថាជា "របបផ្តាច់ការឌីជីថល" ដែលរដ្ឋាភិបាលប្រើប្រាស់ និងពិនិត្យតាមដានប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីគាបសង្កត់ និងគំរាមកំហែងដល់បក្សពួកប្រឆាំងនយោបាយ។ ទោះបីជាប្រព័ន្ធផ្សព្វផ្សាយសង្គម ជាពិសេស Facebook

អាចជាវេទិកាដ៏សំខាន់សម្រាប់ការពិភាក្សា និងព័ត៌មាននយោបាយ អ្នកជំនាញឯករាជ្យដែលមានការប្រឹក្សាយោបល់ដោយក្រុមប្រឹក្សាភិបាលបានរាយការណ៍ថា "មានខ្លឹមសារតិចតួចបំផុតនៅក្នុងប្រព័ន្ធអេកូឡូស៊ី Facebook ជាភាសាខ្មែរ ដែលមិនមានការគាំទ្រដល់រដ្ឋាភិបាល"។ ការបំភិតបំភ័យ និងការគំរាមកំហែងនៃអំពើហិង្សា និងការចាប់ខ្លួនចំពោះសកម្មភាពរិះគន់មកលើលោក ហ៊ុន សែន និងរដ្ឋាភិបាលបានក្លាយជាលក្ខណៈពិសេសមួយនៃសកម្មភាពលើអនឡាញ។ លើសពីនេះ រដ្ឋាភិបាលបានស្នើឱ្យគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសរបស់អ៊ីនធឺណិតនៅកម្ពុជា តាមរយៈ "ច្រកអ៊ីនធឺណិតថ្នាក់ជាតិ"។ យោងតាមក្រុមសង្គមស៊ីវិលកម្ពុជា ប្រព័ន្ធនេះនឹងបញ្ជូនចរាចរណ៍អ៊ីនធឺណិតតាមរយៈម៉ាស៊ីនមេរបស់រដ្ឋាភិបាល និងអាចឱ្យរដ្ឋាភិបាលងាយស្រួលចាប់ផ្ដើមបិទប្រព័ន្ធផ្សព្វផ្សាយសង្គម និងអ៊ីនធឺណិតកាន់តែងាយស្រួល បង្ខំក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិតឱ្យទប់ស្កាត់ ឬរឹតបន្តឹងខ្លឹមសារ បង្កើនសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីធ្វើការឃ្លាំមើលសកម្មភាពលើអ៊ីនធឺណិតរបស់អ្នកប្រើប្រាស់ ហើយតម្រូវឱ្យប្រតិបត្តិករប្រមូល និងរក្សាទុកទិន្នន័យជាច្រើន។ នៅខែកុម្ភៈ ឆ្នាំ ២០២២ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានប្រកាសថាការអនុវត្តច្រកអ៊ីនធឺណិតថ្នាក់ជាតិនឹងត្រូវបានពន្យារពេលដោយសារជំងឺរាតត្បាត COVID-១៩ ប៉ុន្តែមិនមានការបង្ហាញថាគម្រោងនេះត្រូវបានបោះបង់ចោលជាអចិន្ត្រៃយ៍នោះទេ។

នៅឆ្នាំ ២០២០ Meta បានបោះពុម្ពផ្សាយសេចក្ដីសង្ខេបអំពី និងការឆ្លើយតបរបស់ខ្លួនចំពោះការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្ស ដែលខ្លួនទទួលបានពីអាជីវកម្មសម្រាប់ទំនួលខុសត្រូវសង្គម (BSR) នៃសកម្មភាពរបស់ក្រុមហ៊ុនក្នុងប្រទេសកម្ពុជា។ BSR បានរកឃើញថា Facebook មាន "សារៈសំខាន់ចំពោះសេរីភាពនៃព័ត៌មាន និងការបញ្ចេញមតិនៅក្នុងប្រទេស ដែលស្ថានីយវិទ្យុ FM ត្រូវបានបិទ ហើយប្រព័ន្ធបោះផ្សាយ ប្រព័ន្ធផ្សព្វផ្សាយ វិទ្យុ និងទូរទស្សន៍ស្ទើរតែទាំងអស់ត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាល"។ នៅពេលពិចារណាលើសំណុំរឿងនេះ ក្រុមប្រឹក្សាភិបាលទទួលបានសិទ្ធិចូលប្រើប្រាស់របាយការណ៍ពេញលេញដោយ BSR ប៉ុន្តែ Meta បន្តចាត់ថ្នាក់វាជាការសម្ងាត់។ ជាការឆ្លើយតបទៅនឹងសំណួររបស់ក្រុមប្រឹក្សាភិបាល Meta បានបញ្ជាក់ថា ខ្លួនមិនបានធ្វើការវាយតម្លៃពេញលេញលើទំព័រ និងគណនីរបស់លោក ហ៊ុន សែន នោះទេ ប៉ុន្តែទំព័រដែលជាប់ការសង្ស័យមានខ្លឹមសារមួយចំណែកដែលត្រូវបានដកចេញដោយសារតែការរំលោភបំពានលើគោលការណ៍ស្ដីពីអំពើហិង្សា និងការញុះញង់កាលពីខែធ្នូ ឆ្នាំ ២០២២។

Meta បានបញ្ជូនសំណុំរឿងនេះបន្តទៅក្រុមប្រឹក្សាភិបាលដោយបញ្ជាក់ថាសំណុំរឿងនេះពាក់ព័ន្ធនឹ

ងតុល្យភាពដ៏លំបាកវាងគុណតម្លៃរបស់ក្រុមហ៊ុនក្នុងការរក្សា "សុវត្ថិភាព" និង "សិទ្ធិបញ្ចេញមតិ" ក្នុងការសម្រេចថាតើពេលណាត្រូវអនុញ្ញាតឱ្យបន្តមានសុន្ទរកថាដែលបំពានលើគោលការណ៍ស្ដីពីអំពើហិង្សា និងការញុះញង់ដោយមេដឹកនាំនយោបាយនៅលើវេទិការបស់ខ្លួន។ Meta បានស្នើឱ្យក្រុមប្រឹក្សាភិបាលផ្ដល់ការណែនាំអំពីរបៀបវាយតម្លៃខ្លឹមសារបែបនេះ ជាពិសេសនៅក្នុងបរិបទនៃរបបផ្តាច់ការ ដែលសិទ្ធិទទួលបានព័ត៌មានស្ថិតក្នុងហានិភ័យ។

## 3. សិទ្ធិអំណាច និងវិសាលភាពរបស់ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យ

ក្រុមប្រឹក្សាភិបាលមានសិទ្ធិអំណាចក្នុងការពិនិត្យមើលសេចក្តីសម្រេចដែល Meta ដាក់បញ្ជូនដើម្បីពិនិត្យមើល (កតិកាសញ្ញា មាត្រា ២ ផ្នែក ១ ច្បាប់មាត្រា ២ ផ្នែក ២.១.១)។ ក្រុមប្រឹក្សាភិបាលក៏មានសិទ្ធិអំណាចក្នុងការពិនិត្យមើលសេចក្តីសម្រេចរបស់ Meta បន្ទាប់ពីមានការប្តឹងតវ៉ាពីបុគ្គលដែលបានរាយការណ៍ពីមុនលើខ្លឹមសារដែលត្រូវបានបន្តរក្សាទុក (កតិកាសញ្ញា មាត្រា ២ ផ្នែក ១ ច្បាប់មាត្រា ៣ ផ្នែក ១)។ ក្រុមប្រឹក្សាភិបាលអាចប្រកាន់យកឬបដិសេធសេចក្តីសម្រេចរបស់ Meta (មាត្រា ៣ ផ្នែក ៥) ហើយសេចក្តីសម្រេចចងភ្ជាប់កាតព្វកិច្ចលើក្រុមហ៊ុន (កតិកាសញ្ញា មាត្រា ៤)។ Meta ក៏ត្រូវតែវាយតម្លៃលទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចរបស់ខ្លួនទាក់ទងនឹងខ្លឹមសារដូចគ្នាបេះបិទដែលមានបរិបទស្របគ្នា (កតិកាសញ្ញា មាត្រា ៤)។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចរួមបញ្ចូលនូវអនុសាសន៍ដែលមិនជាប់កាតព្វកិច្ចដែល Meta ត្រូវតែឆ្លើយតប (កតិកាសញ្ញា មាត្រា ៣ ផ្នែក ៤ មាត្រា ៤)។ ករណីដែល Meta ប្តេជ្ញាធ្វើសកម្មភាពលើអនុសាសន៍ ក្រុមប្រឹក្សាភិបាលពិនិត្យតាមដានការអនុវត្តរបស់ពួកគេ។

## 4. ប្រភពនៃសិទ្ធិអំណាច និងសេចក្តីណែនាំ

ស្តង់ដារ និងគំរូខាងក្រោមបានជះឥទ្ធិពលលើការវិភាគរបស់ក្រុមប្រឹក្សាភិបាលក្នុងសំណុំរឿងនេះ៖

I. *សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យ៖*

សេចក្តីសម្រេចពីមុនដែលពាក់ព័ន្ធបំផុតរបស់ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យរួមមាន៖

- "ការិយាល័យកិច្ចការទំនាក់ទំនង Tigray" (សេចក្តីសម្រេចអំពីសំណុំរឿង ២០២២-០០៦-FB-MR)

- “ការផ្អាកសិទ្ធិចូលប្រើប្រាស់របស់អតីតប្រធានាធិបតី លោកត្រាំ” (សេចក្តីសម្រេចអំពីសំណុំរឿង ២០២១-០០១-FB-FBR)

II. *គោលការណ៍ខ្លឹមសាររបស់ Meta៖*

ហេតុផលគោលការណ៍សម្រាប់ស្តង់ដារសហគមន៍ស្តីពីអំពើហិង្សា និងការញុះញង់របស់ Facebook ពន្យល់ថាគោលការណ៍ត្រូវបានរៀបចំឡើង “ក្នុងគោលបំណងទប់ស្កាត់ការបំផ្លាញដោយគ្មានអ៊ីនធឺណិតសក្តានុពលដែលអាចទាក់ទងនឹងខ្លឹមសារនៅលើ Facebook” និងពន្យល់ថានៅពេល Meta “យល់ថាមនុស្សជាទូទៅបង្ហាញពីការមើលងាយ ឬការមិនយល់ស្របតាមរយៈការគំរាមកំហែង ឬការអំពាវនាវឱ្យមានអំពើហិង្សាក្នុងវិធីមិនធ្ងន់ធ្ងរ [ក្រុមហ៊ុន] ដកភាសាដែលញុះញង់ ឬសម្រួលអំពើហិង្សាធ្ងន់ធ្ងរចេញ”។ គោលការណ៍នោះចែងបន្ថែមទៀតថា Meta ដកចេញនូវខ្លឹមសារ បិទគណនី និងធ្វើការជាមួយភ្នាក់ងារអនុវត្តច្បាប់ “នៅពេលដែល [ខ្លួន] ជឿថាមានហានិភ័យពិតប្រាកដក្នុងការធ្វើបាបរាងកាយ ឬការគំរាមកំហែងដោយផ្ទាល់ដល់សុវត្ថិភាពសាធារណៈ”។ Meta បញ្ជាក់ថាខ្លួនព្យាយាម “ពិចារណាភាសា និងបរិបទ ដើម្បីបែងចែកសេចក្តីថ្លែងការណ៍ធម្មតាពីខ្លឹមសារដែលបង្កើតជាការគំរាមកំហែងដែលអាចទុកចិត្តបាន”។

គោលការណ៍នេះហាមឃាត់ជាពិសេសលើ “ការគំរាមកំហែងដែលអាចនាំឱ្យមានការស្លាប់” (អំពើហិង្សាកម្រិតធ្ងន់ធ្ងរ) និង “ការគំរាមកំហែងដែលនាំឱ្យមានរបួសធ្ងន់ធ្ងរ (អំពើហិង្សាពាក់កណ្តាលធ្ងន់ធ្ងរ)” ចំពោះបុគ្គលឯកជន បុគ្គលដែលមិនបានបញ្ជាក់ឈ្មោះ ឬបុគ្គលសាធារណៈអនីតិជន និងកំណត់ការគំរាមកំហែងថារួមបញ្ចូលទាំង “សេចក្តីថ្លែងការណ៍អំពីចេតនាប្រព្រឹត្តអំពើហិង្សា” “សេចក្តីថ្លែងការណ៍ដែលគាំទ្រដល់អំពើហិង្សា” ឬ “សេចក្តីថ្លែងការណ៍តាមចង់បាន ឬតាមលក្ខខណ្ឌដើម្បីប្រព្រឹត្តអំពើហិង្សា”។ គោលការណ៍ណែនាំផ្ទៃក្នុងអំពីរបៀបអនុវត្តគោលការណ៍នេះក៏ពន្យល់ថា “ខ្លឹមសារដែលបំពាន ប្រសិនបើខ្លឹមសារនោះត្រូវបានចែករំលែកនៅក្នុងបរិបទថ្កោលទោស ឬបង្កើនការយល់ដឹង” ត្រូវបានអនុញ្ញាត។

ការវិភាគរបស់ក្រុមប្រឹក្សាភិបាលលើគោលការណ៍ខ្លឹមសារត្រូវបានកំណត់ដោយការប្តេជ្ញាចិត្តរបស់ Meta ចំពោះសិទ្ធិបញ្ចេញមតិ ដែលក្រុមហ៊ុនបរិយាយថា “សំខាន់បំផុត”៖

> *គោលដៅនៃស្តង់ដារសហគមន៍របស់យើង គឺដើម្បីបង្កើតកន្លែងសម្រាប់ការបង្ហាញអារម្មណ៍ និងផ្តល់សិទ្ធិបញ្ចេញមតិដល់អ្នកប្រើប្រាស់។ Meta*

*ចង់ឱ្យអ្នកប្រើប្រាស់អាចនិយាយដោយបើកចំហអំពីបញ្ហាដែលសំខាន់ចំពោះពួកគេ ទោះបីជាអ្នកខ្លះអាចជំទាស់ ឬយល់ថាពួកគេអាចជំទាស់បានក៏ដោយ។*

Meta ដាក់កំហិតលើ "សិទ្ធិបញ្ចេញមតិ" ទាក់ទងនឹងគុណតម្លៃបួន "សុវត្ថិភាព" ដែលពាក់ព័ន្ធបំផុតក្នុងសំណុំរឿងនេះ៖

*ក្រុមហ៊ុនប្តេជ្ញាធ្វើឱ្យ Facebook ក្លាយជាកន្លែងដ៏មានសុវត្ថិភាព។ យើងដកចេញនូវខ្លឹមសារដែលអាចរួមចំណែកបង្កហានិភ័យនៃគ្រោះថ្នាក់ដល់សុវត្ថិភាពរាងកាយរបស់មនុស្ស។ ខ្លឹមសារដែលគំរាមកំហែងអ្នកប្រើប្រាស់ ដែលអាចនាំឱ្យមានការបំភិតបំភ័យ ផាត់ចេញ ឬបំបិទមាត់អ្នកដទៃ និងមិនអនុញ្ញាតនៅលើ Facebook ទេ។*

ក្នុងការពន្យល់ពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះ "សិទ្ធិបញ្ចេញមតិ" Meta បញ្ជាក់ថា "ក្នុងករណីខ្លះ យើងអនុញ្ញាតឱ្យមានខ្លឹមសារ - ដែលនឹងផ្ទុយពីស្តង់ដាររបស់យើង ប្រសិនបើវាជាខ្លឹមសារមានភាពស័ក្តិសមជាព័ត៌មាន និងជាផលប្រយោជន៍សាធារណៈ"។ គេហៅវាថាជា[ការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាន]។ វាគឺជាការលើកលែងគោលការណ៍ទូទៅដែលអាចអនុវត្តបានចំពោះស្តង់ដារសហគមន៍ទាំងអស់។ ដើម្បីប្រើប្រាស់ការអត់ឱន Meta ធ្វើតេស្តតុល្យភាព ដោយវាយតម្លៃផលប្រយោជន៍សាធារណៈចំពោះខ្លឹមសារធៀបនឹងហានិភ័យបង្កគ្រោះថ្នាក់។ Meta លើកឡើងថាក្រុមហ៊ុនវាយតម្លៃថាតើខ្លឹមសារ "ប្រឈមមុខនឹងការគំរាមកំហែងជិតមកដល់ចំពោះសុខភាពសាធារណៈ ឬសុវត្ថិភាព ឬផ្តល់ជាមតិដល់ទស្សនៈដែលកំពុងត្រូវបានជជែកដេញដោលជាផ្នែកនៃនីតិវិធីនយោបាយ"។ ទាំងការវាយតម្លៃផលប្រយោជន៍សាធារណៈ និងការបង្កគ្រោះថ្នាក់គឺគិតគូរពីស្ថានភាពរបស់ប្រទេស ដូចជាថាតើការបោះឆ្នោត ឬជម្លោះកំពុងតែកើតមានឬទេ និងថាតើមានសារព័ត៌មានសេរីឬទេ។ Meta បញ្ជាក់ថាមិនមានការសន្មតណាថាខ្លឹមសារនោះគឺជាផលប្រយោជន៍សាធារណៈដោយផ្អែកតែលើមូលដ្ឋាននៃអត្តសញ្ញាណរបស់អ្នកនិយាយនោះទេ ឧទាហរណ៍អត្តសញ្ញាណរបស់ពួកគេជាអ្នកនយោបាយជាដើម។ Meta លើកឡើងថាខ្លួនដកចេញនូវខ្លឹមសារ "ទោះបីជាវាមានកម្រិតនៃភាពស័ក្តិសមជាព័ត៌មានខ្លះក៏ដោយ ពេលដែលការបន្តរក្សាទុកនោះបង្ហាញពីហានិភ័យបង្កគ្រោះថ្នាក់ដូចជាការបង្កគ្រោះថ្នាក់ដល់រាងកាយ អារម្មណ៍ និងហិរញ្ញវត្ថុ ឬការគំរាមកំហែងផ្ទាល់ដល់សុវត្ថិភាពសាធារណៈ"។

ជាការឆ្លើយតបទៅនឹងសំណុំរឿង "ការផ្អាកសិទ្ធិចូលប្រើប្រាស់របស់អតីតប្រធានាធិបតី លោក ត្រាំ" Meta បានបង្កើតគោលការណ៍មួយស្តីពី[ការរឹតបន្តឹងគណនីរបស់បុគ្គលសាធារណៈក្នុងអំឡុងពេលចលាចលស៊ីវិល]។ គោលការណ៍នេះទទួលស្គាល់ថា

“ការរឹតបន្តឹងស្តង់ដារអាចមិនសមស្របទៅនឹងការបំពាន ឬអាចមិនគ្រប់គ្រាន់ដើម្បីកាត់បន្ថយហានិភ័យបង្កគ្រោះថ្នាក់បន្ថែមទៀត ក្នុងករណីដែលបុគ្គលសាធារណៈបង្ហោះខ្លឹមសារក្នុងអំឡុងពេលមានអំពើហិង្សា ឬចលាចលស៊ីវិលដែលកំពុងកើតមាន”។ ក្រុមប្រឹក្សាភិបាលកត់សម្គាល់ថា ទាំងអំពើហិង្សា ឬចលាចលស៊ីវិលដែលកំពុងកើតមាន មិនត្រូវបានបញ្ជាក់នៅក្នុងគោលការណ៍នោះទេ។ គោលការណ៍នេះទទួលស្គាល់ថាការគំរាមកំហែងពីបុគ្គលសាធារណៈបង្កហានិភ័យគ្រោះថ្នាក់ខ្ពស់ នៅពេលដែលពួកគេបំពានគោលការណ៍របស់ Meta និងកំណត់លក្ខខណ្ឌមួយចំនួនដែលក្រុមហ៊ុនប្រើប្រាស់ដើម្បីវាយតម្លៃថាតើ និងរបៀបរឹតបន្តឹងគណនីរបស់ពួកគេ។

### *III. ទំនួលខុសត្រូវសិទ្ធិមនុស្សរបស់ Meta*

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស (UNGP) ដែលត្រូវបានគាំទ្រដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិក្នុងឆ្នាំ ២០១១ បង្កើតក្របខណ្ឌស្ម័គ្រចិត្តសម្រាប់ទំនួលខុសត្រូវសិទ្ធិមនុស្សនៃអាជីវកម្មឯកជន។ នៅឆ្នាំ ២០២១ Meta បានប្រកាសគោលការណ៍សិទ្ធិមនុស្សសាជីវកម្មរបស់ខ្លួន ដែលខ្លួនបានអះអាងឡើងវិញនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្សស្របតាម UNGP។ ការវិភាគរបស់ក្រុមប្រឹក្សាភិបាលអំពីទំនួលខុសត្រូវសិទ្ធិមនុស្សរបស់ Meta ក្នុងករណីនេះត្រូវបានកំណត់ដោយស្តង់ដារអន្តរជាតិដូចខាងក្រោម៖

- សិទ្ធិសេរីភាពនៃការបញ្ចេញទស្សនៈ និងការបញ្ចេញមតិ៖ មាត្រា ១៩ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR), សេចក្តីពន្យល់ទូទៅលេខ ៣៤, គណៈកម្មាធិការសិទ្ធិមនុស្ស, ឆ្នាំ ២០១១, ផែនការសកម្មភាពរបស់រ៉ាបាត, អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសេរីភាពនៃការបញ្ចេញមតិ របាយការណ៍៖ A/HRC/៣៨/៣៥ (២០១៨) និង A/៧៤/៤៨៦ (២០១៩)។
- សេរីភាពនៃការជួបប្រជុំដោយសន្តិវិធី៖ មាត្រា ២១ ICCPR។
- សិទ្ធិទទួលបានសន្តិសុខរាងកាយ៖ មាត្រា ៩ ICCPR។
- សិទ្ធិរស់រានមានជីវិត៖ មាត្រា ៦ ICCPR។
- សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិបោះឆ្នោត៖ មាត្រា ២៥, ICCPR។

## 5. ការដាក់ជូនរបស់អ្នកប្រើប្រាស់

បន្ថែមពីលើការបញ្ជូនសំណុំរឿងបន្តដោយ Meta អ្នកប្រើប្រាស់ក៏បានប្តឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់ Meta ក្នុងការរក្សាខ្លឹមសារនៅលើ Facebook ទៅកាន់ក្រុមប្រឹក្សាភិបាលផងដែរ។ ក្នុងការប្តឹងជំទាស់នោះ អ្នកប្រើប្រាស់បានពន្យល់ថា លោក ហ៊ុន សែន បានគំរាមបែបនេះក្នុងឱកាសមុនៗ។ ជាក់ស្តែង

អ្នកប្រើប្រាស់បានកត់សម្គាល់ថា ក្នុងការបោះឆ្នោតទូទៅខែកក្កដា ឆ្នាំ ២០២៣ នេះ លោក ហ៊ុន សែន តែងតែប្រើប្រាស់ Facebook ដើម្បីគំរាមកំហែងអ្នកដទៃដោយហិង្សា និងបង្ក្រាបសកម្មភាពបក្សប្រឆាំង។

## 6. ការដាក់ជូនរបស់ Meta

Meta បានពន្យល់ថា ខណៈពេលដែលអ្នកពិនិត្យមើលដោយមនុស្សជាបឋមបានវាយតម្លៃខ្លឹមសារសំណុំរឿងថាមិនមានការបំពាន បន្ទាប់ពីវាត្រូវបានបញ្ជូនទៅកាន់អ្នកជំនាញផ្នែកគោលការណ៍ និងសាច់រឿងនៃវិវាទសម្រាប់ការពិនិត្យមើលបន្ថែម ក្រុមហ៊ុនបានសម្រេចថាវាបានបំពានលើគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់ ប៉ុន្តែគួរតែបន្តរក្សាទុកនៅលើវេទិកាស្របតាមគោលការណ៍ស្តីពីការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាន។

នៅពេលបញ្ជូនបន្ត Meta បានកំណត់ថាការដកស្រង់ពីរចំណុចពីសម្តីរបស់លោកហ៊ុនសែន បានបំពានគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់៖ ពោលគឺជម្រើសដែលផ្តល់ជូនគូប្រជែងនយោបាយរបស់គាត់រវាង “ប្រព័ន្ធច្បាប់” និង “ដំបង” និងការគំរាមកំហែងរបស់គាត់ក្នុង “ការប្រមូលមនុស្សរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីតវ៉ា និងវាយដំលើអ្នក”។ Meta បានបញ្ជាក់ថា ដោយផ្អែកលើបរិបទទាំងស្រុងនៃសុន្ទរកថា រួមទាំងព័ត៌មានដែលផ្តល់ដោយក្រុមការងារប្រចាំតំបន់របស់ក្រុមហ៊ុន សេចក្តីយោងដល់ “អ្នក” នៅក្នុងសេចក្តីថ្លែងការណ៍ទាំងនេះ គឺសំដៅទៅលើគូប្រជែងនយោបាយរបស់លោក ហ៊ុន សែន នៅក្នុងគណបក្សភ្លើងទៀន និងអាចជាគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយនៅពេលនេះ។

ដោយថ្លឹងថ្លែងពីហានិភ័យបង្កគ្រោះថ្នាក់ប្រឆាំងនឹងអត្ថប្រយោជន៍ដែលអាចកើតមាននៃការអនុញ្ញាតឱ្យមានខ្លឹមសារនៅលើ Facebook ស្របតាមគោលការណ៍អត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាន Meta បានកត់សម្គាល់ថាសុន្ទរកថាភាគច្រើននៃរយៈពេលមួយម៉ោង និង ៤១ នាទីទាក់ទងនឹងអភិបាលកិច្ច ឬនយោបាយ ដូចជាទំនាក់ទំនងរបស់កម្ពុជាជាមួយប្រទេសចិន និងជំងឺរាតត្បាត COVID-១៩។ Meta បានលើកឡើងថា សុន្ទរកថានយោបាយរបស់មេដឹកនាំប្រទេសមួយមានគុណតម្លៃផលប្រយោជន៍សាធារណៈខ្ពស់ ជាពិសេសនៅក្នុងឆ្នាំបោះឆ្នោត។ ផ្ទុយទៅវិញ យោងតាមការវាយតម្លៃរបស់ក្រុមហ៊ុន ការបំពានផ្នែកខ្លះនៃសុន្ទរកថាមានរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ និងត្រូវបានចាត់ក្នុងកម្រិតនៃពាក់កណ្តាលធ្ងន់ធ្ងរនៃគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់។

Meta
បានបញ្ជាក់ថាសាធារណៈជនមានការចាប់អារម្មណ៍ក្នុងការស្តាប់សារព្រមានអំពីអំពើហិង្សាដែល
អាចកើតមានដោយរដ្ឋាភិបាលរបស់ខ្លួន
ជាពិសេសនៅពេលដែលការគំរាមកំហែងទាំងនោះមិនត្រូវបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សា
យក្នុងស្រុក។ Meta បានទទួលព័ត៌មានតាមរយៈក្រុមការងារប្រចាំតំបន់របស់ក្រុមហ៊ុនថា
ទោះបីជាប្រព័ន្ធផ្សព្វផ្សាយក្នុងតំបន់
ដែលមិនមានភាពចាំបាច់ឱ្យប្រជាជនក្នុងប្រទេសកម្ពុជាចូលប្រើប្រាស់ប្រព័ន្ធនោះ
បានរាយការណ៍អំពីការគំរាមកំហែងក៏ដោយ
ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកមិនបានធ្វើការរាយការណ៍បែបនោះទេ។ ដើម្បីគាំទ្រការវាយតម្លៃនេះ
Meta បានដកស្រង់របាយការណ៍ប្រព័ន្ធផ្សព្វផ្សាយចំនួនពីរ
ស្តីពីធាតុផ្សំអំពើហិង្សានៃសុន្ទរកថារបស់លោក ហ៊ុន សែន៖ សម្រង់មួយមកពី *បាងកកប៉ុស្ដិ៍*
និងសម្រង់មួយទៀតមកពី *សំឡេងប្រជាធិបតេយ្យ* ស្ថាប័នសារព័ត៌មានឯករាជ្យដែលមាន
មូលដ្ឋាននៅក្នុងប្រទេសកម្ពុជាដែលត្រូវបានរដ្ឋាភិបាលបិទកាលពីពេលថ្មីៗនេះ។ Meta
ជឿជាក់ថា នៅក្រោមកាលៈទេសៈទាំងនេះ Facebook អាច
“ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយការយល់ដឹងអំពីហានិភ័យសុវត្ថិភាពដែលអាចកើត
មាន”។ ទាក់ទងនឹងបរិបទនេះ Meta បានកត់សម្គាល់ថា
ខ្លឹមសារក្នុងសំណុំរឿងនេះមិនពាក់ព័ន្ធនឹងអំពើហិង្សា
ឬជម្លោះប្រដាប់អាវុធដែលកំពុងបន្តកើតមានទេ
ដូចខ្លឹមសារដែលត្រូវបានពិចារណានៅក្នុងសំណុំរឿង
“ការផ្អាកសិទ្ធិចូលប្រើប្រាស់របស់អតីតប្រធានាធិបតីលោកត្រាំ” និង
“ការិយាល័យកិច្ចការទំនាក់ទំនង Tigray” នោះទេ។ យ៉ាងណាក៏ដោយ Meta ទទួលស្គាល់ថា មាន
ការបោះឆ្នោតនៅពេលខាងមុខ ហើយថា លោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាបាន
បង្ក្រាបឥស្សរជននយោបាយ និងប្រព័ន្ធផ្សព្វផ្សាយរបស់បក្សប្រឆាំង។

Meta ពន្យល់ថា ក្រុមហ៊ុនមិនអាចបញ្ជាក់ពីចេតនារបស់លោក ហ៊ុន សែនបានទេ នៅពេលដែល
គាត់ថ្លែងសុន្ទរកថាទាំងនេះ។ ទោះយ៉ាងណាក៏ដោយ Meta បានកត់សម្គាល់ថា
“ដោយពិចារណាលើការប្រើប្រាស់នីតិវិធីតុលាការរបស់ CPP
ដើម្បីធ្វើឱ្យចុះខ្សោយនៃឥទ្ធិពលគូប្រជែងនយោបាយ
វាហាក់ដូចជាគាត់បានជ្រើសរើសប្រើតុលាការជាជាងកងកម្លាំង
បើទោះបីជាការធ្វើបែបនេះមិនរារាំងដល់លទ្ធភាពនៃអំពើហិង្សានាពេលអនាគតក៏ដោយ”។
ជាការឆ្លើយតបទៅនឹងសំណួររបស់ក្រុមប្រឹក្សាភិបាល Meta បានបញ្ជាក់ថា
ខ្លួនដឹងពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា “រួមទាំងគំរូរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន
ដែលចូលរួមក្នុងសុន្ទរកថាដែលគំរាមកំហែងទាំងអំពើហិង្សា
ឬការប្រើប្រាស់ប្រព័ន្ធតុលាការប្រឆាំងនឹងគូប្រជែងនយោបាយ”។

Meta ជឿថាសេចក្តីសម្រេចរបស់ខ្លួនគឺស្របនឹងគុណតម្លៃរបស់ក្រុមហ៊ុន ក៏ដូចជាគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ។ Meta បានលើកឡើងថាកត្តាសំខាន់ៗក្នុងការកំណត់ថាខ្លឹមសារនេះមិនតម្រូវឱ្យមានការដកចេញគឺទាក់ទងនឹងបរិបទ និងកង្វះនៃគ្រោះថ្នាក់ដែលជិតមកដល់។ ការគំរាមកំហែងក្នុងសំណុំរឿងនេះគឺ "មិនជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ ឬព្រឹត្តិការណ៍ហិង្សាដែលកំពុងបន្តកើតមាន" និង "មិនមានភាពជាក់លាក់"។ ទោះជាយ៉ាងណាក៏ដោយ Meta បានទទួលស្គាល់ "បញ្ហាពិបាកក្នុងការគ្រប់គ្រងការគំរាមកំហែងដែលខ្វះទំនាក់ទំនងទៅនឹងអំពើហិង្សាដែលជិតមកដល់ ប៉ុន្តែទោះជាយ៉ាងណាអាចរួមចំណែកដល់បរិយាកាសនៃការភ័យខ្លាចនៅពេលដែលចេញសារដោយរដ្ឋាភិបាលផ្តាច់ការ"។

ក្រុមប្រឹក្សាភិបាលបានសួរសំណួរ Meta ចំនួន ១៥ ជាលាយលក្ខណ៍អក្សរ។ សំណួរទាក់ទងនឹង៖ ការបំពានកន្លងមកដោយទំព័រ និងគណនីរបស់លោក ហ៊ុន សែន, កត្តាបរិបទដែលត្រូវបានពិចារណានៅពេលអនុវត្តការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាន, កត្តាបរិបទដែលត្រូវបានពិចារណានៅពេលអនុវត្តគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់, ទំនាក់ទំនងរបស់ Meta ជាមួយអាជ្ញាធររដ្ឋាភិបាលក្នុងប្រទេសកម្ពុជា, បញ្ជីពិនិត្យផ្ទៀងផ្ទាត់នៃការពិនិត្យមើលបន្ទាប់បន្សំលើការឆ្លើយតបដំបូង និងការបែងចែកធនធានរបស់ Meta សម្រាប់ការងារប្រតិបត្តិការ និងការងារផលិតផលទាក់ទងនឹងខ្លឹមសារជាភាសាខ្មែរនៅប្រទេសកម្ពុជា។ Meta បានឆ្លើយសំណួរទាំងអស់។

## 7. អត្ថាធិប្បាយសាធារណៈ

ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យបានទទួលអត្ថាធិប្បាយសាធារណៈចំនួន ១៨ ពាក់ព័ន្ធនឹងសំណុំរឿងនេះ។ អត្ថាធិប្បាយចំនួនប្រាំត្រូវបានដាក់ជូនពីអាស៊ីប៉ាស៊ីហ្វិក និងអូសេអានី មតិមួយមកពីអាស៊ីកណ្តាល និងខាងត្បូង មួយមកពីអាមេរិកឡាទីន និងការាបៀន និង ១១ ទៀតមកពីសហរដ្ឋអាមេរិក និងកាណាដា។

សំណើដាក់ជូនរួមមានប្រធានបទដូចខាងក្រោម៖ បរិបទនៃការគាបសង្កត់ផ្នែកនយោបាយ និងការមិនយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្សនៅកម្ពុជា, និទណ្ឌភាពដែលឥស្សរជនរដ្ឋាភិបាលកម្ពុជាធ្វើសកម្មភាពនៅលើ Facebook និងការធ្លាក់ចុះនៃសិទ្ធិសេរីភាពពលរដ្ឋនៅកម្ពុជា។ ក្រុមប្រឹក្សាភិបាលក៏បានស្តាប់ដោយផ្ទាល់ពីតំណាងសង្គមស៊ីវិលដែលបានសង្កត់ធ្ងន់ថា ការគំរាមកំហែង និងការញុះញង់ពីលោក ហ៊ុន សែន គឺជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងជាប្រព័ន្ធដើម្បីបង្កើតបរិយាកាសបង្កការភ័យខ្លាចក្នុងចំណោមគូប្រជែងនយោបាយ និងដើម្បីរារាំងប្រជាជនកម្ពុជាពីការចោទសួររដ្ឋាភិបាល។

ដើម្បីអានអត្ថាធិប្បាយសាធារណៈដែលបានដាក់ជូនសម្រាប់សំណុំរឿងនេះ សូមចុចទីនេះ [បញ្ចូលតំណភ្ជាប់]។

## 8. ការវិភាគរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានជ្រើសរើសសំណុំរឿងនេះ ព្រោះវាផ្តល់ឱកាសដល់ក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យមើលថាតើមេដឹកនាំនយោបាយកំពុងប្រើប្រាស់វេទិការបស់ Meta ក្នុងការញុះញង់ឱ្យមានអំពើហិង្សា និងទប់ស្កាត់បក្សពួកប្រឆាំងនយោបាយ ហើយប្រសិនបើដូច្នេះ តើគួរតែមានផលវិបាកអ្វីខ្លះកើតឡើង។ សំណុំរឿងនេះក្លាយជាអាទិភាពជាយុទ្ធសាស្រ្តរបស់ក្រុមប្រឹក្សាភិបាលនៃការប្រើប្រាស់របស់រដ្ឋាភិបាលលើវេទិកា Meta ក៏ដូចជាការបោះឆ្នោត និងកន្លែងសម្រាប់ពលរដ្ឋ។ ក្រុមប្រឹក្សាភិបាលបានពិនិត្យថាតើខ្លឹមសារនេះគួរតែត្រូវបានដកចេញឬយ៉ាងណាតាមរយៈការវិភាគអំពីគោលការណ៍ខ្លឹមសារ គុណតម្លៃ និងទំនួលខុសត្រូវសិទ្ធិមនុស្សរបស់ Meta។

### 8.1 ការអនុលោមតាមគោលការណ៍ខ្លឹមសាររបស់ Meta

I. *វិធាននៃខ្លឹមសារ*

a. *អំពើហិង្សា និងការញុះញង់*

ក្រុមប្រឹក្សាភិបាលយល់ឃើញថាខ្លឹមសារក្នុងសំណុំរឿងនេះបំពានលើស្តង់ដារសហគមន៍ស្តីពីអំពើហិង្សា និងការញុះញង់ និងត្រូវតែដកចេញពីវេទិកា។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា វីដេអូដែលបានបង្ហោះនោះ រួមបញ្ចូលនូវសេចក្តីថ្លែងការណ៍ច្បាស់លាស់នៃចេតនាញុះញង់មិនត្រឹមតែអំពើហិង្សាកម្រិតពាក់កណ្តាលធ្ងន់ធ្ងរ (របួសធ្ងន់ធ្ងរ) ប៉ុណ្ណោះទេ ប៉ុន្តែក៏មានអំពើហិង្សាកម្រិតធ្ងន់ (ហានិភ័យបង្កការស្លាប់ និងទម្រង់នៃអំពើហិង្សាកម្រិតធ្ងន់ធ្ងរផ្សេងទៀត) ទៅលើគូប្រជែងនយោបាយរបស់លោក ហ៊ុន សែន ដែលបំពានយ៉ាងច្បាស់លើគោលការណ៍ស្តីអំពើហិង្សា និងការញុះញង់។ បរិបទនយោបាយកាន់តែទូលំទូលាយពង្រឹងការសន្និដ្ឋាននោះ៖ លោក ហ៊ុន សែន និងសមាជិកគណបក្សរបស់គាត់បានទាំងគំរាម និងប្រើអំពើហិង្សាលើបក្សពួកប្រឆាំង និងអ្នកគាំទ្រម្តងហើយម្តងទៀត ដោយប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្សព្វផ្សាយការគំរាមកំហែងរបស់ខ្លួន។ ប្រវត្តិនៃអំពើហិង្សា និងការគាបសង្កត់នេះធ្វើឱ្យការគំរាមកំហែងទាំងនោះល្មមនឹងជឿជាក់បាន ហើយនៅក្នុងបរិបទនេះ សេចក្តីថ្លែងការណ៍បែបនេះស្មើនឹងការបំពានធ្ងន់ធ្ងរលើគោលការណ៍នេះ។

តាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល ការថានាត្រឹមត្រូវរបស់លោក ហ៊ុន សែន ដែលថា "យើងមិនញុះញង់ប្រជាពលរដ្ឋ និងលើកទឹកចិត្តប្រជាជនប្រើកម្លាំង" ផ្ទុយពីសារច្បាស់លាស់នៃសុន្ទរកថា និងមិនគួរឱ្យទុកចិត្តនោះទេ។ ក្រុមប្រឹក្សាភិបាលមានការព្រួយបារម្ភ និងមានការងឿងឆ្ងល់ដែលអ្នកពិនិត្យមើលដំបូងបានសន្និដ្ឋានផ្ទុយពីនេះ ប៉ុន្តែកត់សម្គាល់ឃើញថា អ្នកជំនាញប្រចាំប្រទេសរបស់ Meta ដែលកំពុងត្រួតពិនិត្យបានទទួលស្គាល់ថាសារបង្ហោះនេះបានបំពានលើស្តង់ដារអំពើហិង្សា និងការញុះញង់។

ជាការឆ្លើយតបទៅនឹងសំណួររបស់ក្រុមប្រឹក្សាភិបាល Meta បានបញ្ជាក់ថា "ការគំរាមកំហែងក្នុងការប្តឹង ឬប្រើប្រាស់ប្រព័ន្ធផ្លូវច្បាប់ប្រឆាំងនឹងឥស្សរជនគណបក្សប្រឆាំងតែឯកឯង នឹងមិនបំពានលើគោលការណ៍ស្តីពី [អំពើហិង្សា និងការញុះញង់] ទេ ដោយសារការគំរាមកំហែងនោះមិនពាក់ព័ន្ធនឹងការគំរាមកំហែងជាក់ស្តែងនៃអំពើហិង្សានោះទេ"។ Meta បានបង្ហាញពីភាពត្រឹមត្រូវចំពោះជំហរនោះដោយពន្យល់ថា "ក្នុងនាមជាវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម យើងមិនមានតួនាទីកំណត់ដោយឯករាជ្យថាតើការគំរាមកំហែងដោយរដ្ឋាភិបាលក្នុងការប្រើប្រាស់នីតិវិធីផ្លូវច្បាប់នោះជ្រុលហួសហេតុឬអត់នោះទេ"។

ទោះជាវិធីសាស្ត្រនេះអាចជាការសមរម្យនៅពេលដែលការគំរាមកំហែងពិតជា "ធ្វើឡើងដោយឯកឯង" ក៏ដោយ ក៏នោះមិនមានភាពពាក់ព័ន្ធនៅទីនេះទេ។ ករណីដែលរបបមានប្រវត្តិតាមដានតាមរយៈការគំរាមកំហែងនៃអំពើហិង្សាប្រឆាំងនឹងបក្សពួកប្រឆាំងរបស់ខ្លួន ប្រើប្រាស់វេទិការបស់ Meta ក្រុមហ៊ុនត្រូវតែពឹងផ្អែកលើក្រុមការងារ និងអ្នកជំនាញក្នុងតំបន់របស់ខ្លួនដើម្បីវាយតម្លៃថាតើការគំរាមកំហែងក្នុងការប្រើប្រាស់ប្រព័ន្ធផ្លូវច្បាប់ប្រឆាំងនឹងគូប្រជែងនយោបាយមានតម្លៃស្មើគ្នានឹងការគំរាមកំហែង ឬការបំភិតបំភ័យដោយអំពើហិង្សាដែរឬទេ។ នៅក្នុងបរិបទនៃប្រទេសកម្ពុជា ករណីដែលតុលាការត្រូវបានគ្រប់គ្រងដោយគណបក្សកាន់អំណាច និងត្រូវបានប្រើប្រាស់ជាប្រចាំដើម្បីគាបសង្កត់គណបក្សប្រឆាំងនោះ នាយករដ្ឋមន្ត្រីដែលគំរាមដេញបក្សពួកប្រឆាំងរបស់គាត់តាមរយៈប្រព័ន្ធផ្លូវច្បាប់ គឺស្មើនឹងការគំរាមកំហែងបង្កអំពើហិង្សា។ ការគំរាមចាប់ខ្លួនបក្សពួកប្រឆាំងនៅពាក់កណ្តាលអធ្រាត្រមិនស្របនឹងនីតិវិធីត្រឹមត្រូវទេ។ ក្រុមប្រឹក្សាភិបាលក៏បានកត់សម្គាល់អំពីប្រវត្តិនៃគោលដៅបង្កការបំភិតបំភ័យតាមរយៈការប្រើប្រាស់តុលាការដោយមិនត្រឹមត្រូវដោយលោក ហ៊ុន សែន ជាបន្តបន្ទាប់បានក្លាយជាគោលដៅនៃអំពើហិង្សាលើរូបរាងកាយដែលបានចងក្រងជាឯកសារខាងលើ។

### *b. ការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាន*

ក្រុមប្រឹក្សាភិបាលសន្និដ្ឋានថា Meta ប្រព្រឹត្តខុសក្នុងការអនុវត្តការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មានក្នុងករណីនេះ ដោយសារគ្រោះថ្នាក់ដែលបន្តរក្សាខ្លឹមសារនៅលើវេទិកាមានលើសពីផលប្រយោជន៍សាធារណៈក្នុងការផ្សព្វផ្សាយសុន្ទរកថា។

យោងទៅតាម[វិធីសាស្ត្រ]របស់ Meta ចំពោះខ្លឹមសារដែលស័ក្តិសមជាព័ត៌មាន មិនមានការសន្មតណាថាខ្លឹមសារនោះជាព័ត៌មានដែលមានប្រយោជន៍ដោយផ្អែកតែលើអ្នកនិយាយនោះទេ។ នៅក្នុងហេតុផលនៃការសម្រេចចិត្ត Meta បានរាយការណ៍ថា ក្នុងករណីនេះ ក្រុមហ៊ុនបានថ្លឹងថ្លែងពីកត្តាជាច្រើន នៅខាងក្រៅខ្លឹមសារខ្លួនឯង ក្នុងការសម្រេចចិត្តអនុវត្តការលើកលែងសម្រាប់ភាពស័ក្តិសមជាព័ត៌មាន។ Meta បានចាត់ទុកទាំង “កាលៈទេសៈជាក់លាក់តាមប្រទេស និងរចនាសម្ព័ន្ធនយោបាយនៅក្នុងប្រទេសកម្ពុជា រួមទាំងកង្វះសារព័ត៌មានឯករាជ្យ ការរាយការណ៍ពីការគាបសង្កត់របស់គណបក្សប្រឆាំងនយោបាយ និងរបាយការណ៍ពីអង្គការសិទ្ធិមនុស្ស”។

ជាការឆ្លើយតបទៅនឹងសំណួររបស់ក្រុមប្រឹក្សាភិបាល Meta បានលើកឡើងថា កង្វះការផ្សាយព័ត៌មានក្នុងស្រុកអំពីការគំរាមកំហែងមានសារៈសំខាន់បំផុតដែលទាក់ទងដោយផ្ទាល់ទៅនឹងគុណតម្លៃផលប្រយោជន៍សាធារណៈរបស់ខ្លឹមសារជាសារព្រមានដល់ប្រជាជនកម្ពុជា។ វាត្រូវបានធ្វើឡើងដោយផ្អែកលើការវាយតម្លៃរបស់ក្រុមហ៊ុនថា ខណៈពេលដែលប្រព័ន្ធផ្សព្វផ្សាយក្នុងតំបន់បានរាយការណ៍អំពីការគំរាមកំហែងនោះ ការរាយការណ៍ក្នុងស្រុកនៃសុន្ទរកថាមិនបានលើកឡើងអំពីវានោះទេ។ ក្រុមប្រឹក្សាភិបាលកត់សម្គាល់ថា ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយមួយដែលត្រូវបានដកស្រង់ដោយ Meta ក្នុងការគាំទ្រការវាយតម្លៃនេះ: *វិទ្យុសំឡេងប្រជាធិបតេយ្យ*នៅកម្ពុជា បានរាយការណ៍អំពីការគំរាមកំហែងដោយហិង្សានៅក្នុងសុន្ទរកថារបស់លោក ហ៊ុន សែន ហើយថែមទាំងបានអះអាងខ្លួនឯងថាជា “ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងស្រុក” មុនពេលដែលមានការបិទដំណើរការនៅខែកុម្ភៈ ឆ្នាំ ២០២៣។ [របាយការណ៍]មួយដែលផ្តល់ដោយអ្នកជំនាញបានរកឃើញថា ៨២.៦% នៃអ្នកទទួល “ដែលមានសិទ្ធិ” (ពោលគឺអ្នកប្រើប្រាស់ដែលមានអាយុចាប់ពី ១៣ ឆ្នាំឡើងទៅ) នៅក្នុងប្រទេសកម្ពុជាប្រើប្រាស់ Facebook ក្នុងឆ្នាំ ២០២៣។ ដោយពិភាក្សាអំពីហេតុផលនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម [Freedom House] [រាយការណ៍]ថាបន្ទាប់ពីការបោះឆ្នោតទូទៅឆ្នាំ ២០១៨ អ៊ីនធឺណិត “បានក្លាយជាប្រភពនៃព័ត៌មាន និងព័ត៌មានសំខាន់មួយសម្រាប់ប្រជាជនកម្ពុជា ហើយប្រព័ន្ធផ្សព្វផ្សាយសង្គមបានអនុញ្ញាតឱ្យមានការរីកសាយភាយខ្លឹមសារកាន់តែសម្បូរបែប ដែលគ្មានឥទ្ធិពលពីរដ្ឋាភិបាល”។ Meta ក៏បានកត់សម្គាល់ផងដែរថា “លក្ខណៈប្រហាក់ប្រហែលគ្នានៃការគំរាមកំហែងខ្លះ” នៅក្នុងសុន្ទរកថាបានបញ្ចូលក្នុងសេចក្តីសម្រេច “ថាគុណតម្លៃផលប្រយោជន៍សាធារណៈខ្ពស់ក្នុងការអនុញ្ញាតឱ្យមនុស្សស្តាប់សុន្ទរកថានយោបា

យ . . . មានកម្រិតលើសពីហានិភ័យបង្កគ្រោះថ្នាក់”
និងស័ក្តិសមទទួលបានការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៍មាន។

ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថាគុល្យភាពដ៏ពិបាកនេះត្រូវតែដោះស្រាយ
នៅពេលវាយតម្លៃសុន្ទរកថាដែលបំពានដែលធ្វើឡើងដោយមេដឹកនាំនយោបាយ។
ក្រៅពីកម្រិតនៃការពឹងអាស្រ័យខ្ពស់លើប្រព័ន្ធផ្សព្វផ្សាយសង្គមនៅកម្ពុជា
រដ្ឋាភិបាលបានបិទដំណើរការប្រព័ន្ធផ្សព្វផ្សាយប្រពៃណីឯករាជ្យស្ទើរតែទាំងអស់នៅក្នុងប្រទេស
ដែលបង្កការលំបាកដល់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានឯករាជ្យនិងមិនលំអៀងតាមរ
យៈបណ្តាញផ្សេងទៀត។ លើសពីនេះ
មានទទ្បីករណ៍តម្លាភាពខ្លាំងដែលប្រជាជនកម្ពុជាគួរតែអាចមើលឃើញថាមេដឹកនាំរបស់ខ្លួនកំ
ពុងធ្វើការគំរាមកំហែងប្រឆាំងនឹងពួកបក្សប្រឆាំងនឹងគាត់
ទោះបីជាក្រុមប្រឹក្សាភិបាលកត់សម្គាល់ថាប្រជាជនភាគច្រើននៅក្នុងប្រទេសកម្ពុជានឹងដឹងថា
សមាជិកនៃរបបលោក ហ៊ុន សែន តែងតែចូលរួមនៅក្នុងសុន្ទរកថាបែបនេះក៏ដោយ។

ទោះជាយ៉ាងនេះក្តី ដោយពិចារណាលើការផ្សព្វផ្សាយរបស់លោក ហ៊ុន សែន
នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម
ដែលថាការអនុញ្ញាតឱ្យមានសុន្ទរកថាបែបនេះនៅលើវេទិកាបើកឱកាសឱ្យមានការគំរាមកំហែ
ងរបស់គាត់រីករាលដាលកាន់តែទូលំទូលាយ។ វាក៏បណ្តាលឱ្យមានការកេងប្រវ័ញ្ចលើវេទិការរបស់
Meta ក្រោមឥទ្ធិពលនោះផងដែរ
ដែលរួមចំណែកដល់គ្រោះថ្នាក់ទាំងនេះតាមរយៈការផ្សព្វផ្សាយការគំរាមកំហែង
និងការបំភិតបំភ័យជាលទ្ធផល។
នេះមិនមែនជាសារបង្ហោះរបស់ភាគីទីបីដែលរាយការណ៍អំពីការគំរាមកំហែងរបស់លោក ហ៊ុន
សែន នោះទេ ប៉ុន្តែជាសារបង្ហោះនៅលើគណនី Facebook ផ្លូវការរបស់លោក ហ៊ុន សែន
ដែលបង្ហាញពីការគំរាមកំហែងទាំងនោះ។

ក្រុមប្រឹក្សាភិបាលមានការព្រួយបារម្ភផងដែរថា យុទ្ធនាការបៀតបៀន
និងការបំភិតបំភ័យជាបន្តបន្ទាប់របស់មេដឹកនាំនយោបាយប្រឆាំងនឹងប្រព័ន្ធផ្សព្វផ្សាយឯករា
ជ្យ
និងបក្សពួកប្រឆាំងនយោបាយអាចក្លាយជាកត្តាមួយក្នុងការវាយតម្លៃភាពស័ក្តិសមជាព័ត៍មា
នដែលនាំឱ្យមានខ្លឹមសារដែលបំពានមិនត្រូវបានដកចេញ
និងគណនីមិនទទួលរងការដាក់ទោសពិន័យ។
ឥរិយាបថបែបនេះមិនគួរលើកទឹកចិត្តឱ្យមាននោះទេ។ Meta
គួរតែថ្លឹងថ្លែងឱ្យកាន់តែធ្ងន់ទៅលើសេរីភាពសារព័ត៍មាន
នៅពេលពិចារណាអំពីភាពស័ក្តិសមជាព័ត៍មាន
ដើម្បីកុំឱ្យមានការអត់ឱនចំពោះសុន្ទរកថារបស់រដ្ឋាភិបាលក្នុងស្ថានភាពដែលរដ្ឋាភិបាលនោះ
បានបង្កើតខ្លឹមសារផ្ទាល់របស់ខ្លួនឱ្យកាន់តែមានតម្លៃជាព័ត៍មានដោយការដាក់កំណត់សេរីភា
ពសារព័ត៍មាន។

ជំហររបស់ Meta
ក៏ហាក់ដូចជាសន្មតថាអ្នកដែលមើលខ្លឹមសារដែលបំពាននេះនឹងឃើញខ្លឹមសារនោះថាជាការញុះញង់ និងមិនយល់ព្រមចំពោះខ្លឹមសារនោះទេ។ ទោះជាយ៉ាងក៏ដោយ មានឱកាសតិចតួចដែលអាចសម្តែងភាពមិនពេញចិត្តបែបនេះនៅក្នុងប្រទេសកម្ពុជា និងអនុញ្ញាតឱ្យខ្លឹមសារដែលបំពាននេះបន្តមាននៅលើវេទិកាក្នុងការបង្កហានិភ័យបន្ថែម ដែលធ្វើឱ្យពាក្យសម្ដីហិង្សាពីមេដឹកនាំនយោបាយមានលក្ខណៈធម្មតា។ ជាជាងការជជែកដេញដោលផ្តល់ជាព័ត៌មាន ការអនុវត្តការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មានក្នុងករណីនេះនឹងបង្កការភ័យខ្លាចដល់សន្ទរកថាជាសាធារណៈក្រោមការត្រួតត្រារបស់ ហ៊ុន សែន លើទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយ។

វិធីសាស្ត្ររបស់ Meta
ចំពោះខ្លឹមសារដែលស័ក្តិសមជាព័ត៌មានរក្សាតុល្យភាពផលប្រយោជន៍សាធារណៈធៀបនឹងហានិភ័យបង្កគ្រោះថ្នាក់។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលយល់ឃើញថាការធ្វើតេស្តរក្សាតុល្យភាពនេះមិនអាចសម្រេចបានទេ ក្នុងករណីដែលបុគ្គលសាធារណៈប្រើប្រាស់វេទិការបស់ Meta ដើម្បីញុះញង់ឱ្យមានអំពើហិង្សាដោយផ្ទាល់។ ប្រសិនបើមានផលប្រយោជន៍ជាសាធារណៈគ្រប់គ្រាន់នៅក្នុងពាក្យសម្ដីញុះញង់នោះ វានឹងត្រូវបានរាយការណ៍ដោយទម្រង់មួយចំនួននៃវិជ្ជាជីវៈខាងសារព័ត៌មានភាគីទីបី។ ទោះបីជាខ្លឹមសារដែលរាយការណ៍ បង្កើនការយល់ដឹង ថ្កោលទោស ឬផ្តល់មតិយោបល់លើការញុះញង់ឱ្យមានអំពើហិង្សាដោយបុគ្គលសាធារណៈដោយមិនបានគាំទ្រខ្លឹមសារនោះមិនគួរត្រូវបានហាមឃាត់ក៏ដោយ ក៏ Meta មិនអាចបន្តអនុញ្ញាតឱ្យមានការញុះញង់ដោយផ្ទាល់នៅលើវេទិការបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានភាពស័ក្តិសមជាព័ត៌មាននោះទេ។

## II. *សកម្មភាពអនុវត្តច្បាប់*

ក្រុមប្រឹក្សាភិបាលប្រកាន់ខ្ជាប់ថា ការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មានក្នុងករណីនេះគួរតែត្រូវបានដកហូត ហើយថាខ្លឹមសារគួរតែត្រូវបានដកចេញដោយសារការបំពានលើគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់។ វាមានសារៈសំខាន់ណាស់ដែលវេទិការបស់ Meta មិនត្រូវបានប្រើប្រាស់ជាឧបករណ៍មួយដើម្បីផ្សព្វផ្សាយការគំរាមកំហែងនៃអំពើហិង្សា និងការសងសឹក ដែលមានបំណងបង្ក្រាបបក្សពួកប្រឆាំងនយោបាយ ជាពិសេសក្នុងអំឡុងពេលបោះឆ្នោត ដូចករណីនេះ។ ជាងនេះទៅទៀត ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃការរំលោភបំពាន បរិបទនយោបាយនៅកម្ពុជា ប្រវត្តិរបស់រដ្ឋាភិបាលក្នុងការបំពានសិទ្ធិមនុស្ស ប្រវត្តិរបស់លោក ហ៊ុន សែន ក្នុងការញុះញង់ឱ្យមានអំពើហិង្សាលើគូប្រជែង និងរបៀបដែលគាត់ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមជាយុទ្ធសាស្ត្រដើម្បីផ្សព្វផ្សាយការគំរាមកំ

ហែងបែបនេះ ក្រុមប្រឹក្សាភិបាលសន្និដ្ឋានថា Meta គួរផ្អាកជាបន្ទាន់នូវទំព័រ Facebook
និងគណនី Instagram ផ្លូវការរបស់លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា។
ទោះបីជាក្រុមប្រឹក្សាភិបាលមិនមានតួនាទីក្នុងការកំណត់រយៈពេលនៃការផ្អាកនៅក្នុងករណីលើ
កដំបូងនោះក៏ដោយ ក៏ក្រុមប្រឹក្សាភិបាលរក្សាជំហរថាទំព័រ
និងគណនីគួរតែត្រូវបានផ្អាកយ៉ាងហោចណាស់រយៈពេលប្រាំមួយខែ ដើម្បីផ្តល់ពេលឱ្យ Meta
ពិនិត្យមើលស្ថានភាព និងកំណត់ជារយៈពេលជាក់លាក់មួយ។ លើសពីនេះទៅទៀត
មុននឹងបញ្ចប់ការផ្អាកនេះ Meta
គួរតែអនុវត្តការវាយតម្លៃដើម្បីកំណត់ថាតើហានិភ័យចំពោះសុវត្ថិភាពសាធារណៈបានធ្លាក់ចុះ
ដែរឬទេ ដោយអញ្ជើញភាគីពាក់ព័ន្ធក្នុងតំបន់ឱ្យចែករំលែកព័ត៌មានពាក់ព័ន្ធ។

ជាផ្នែកនៃការឆ្លើយតបរបស់ខ្លួនចំពោះអនុសាសន៍របស់ក្រុមប្រឹក្សាភិបាលនៅក្នុងសំណុំរឿង
"ការផ្អាកសិទ្ធិចូលប្រើប្រាស់របស់អតីតប្រធានាធិបតី លោកត្រាំ" Meta
បានបង្កើតគោលការណ៍ស្តីពីការដាក់រឹតបន្តឹងលើគណនីរបស់បុគ្គលសាធារណៈ (សូមមើលផ្នែក
៤ ខាងលើ)។ គោលការណ៍នេះអនុវត្តចំពោះ
"បុគ្គលសាធារណៈដែលបង្ហោះខ្លឹមសារអំឡុងពេលមានអំពើហិង្សា ឬចលាចលស៊ីវិលជាបន្ទាប់"។
ប្រឆាំងនឹងប្រវត្តិនៃការគាបសង្កត់ផ្នែកនយោបាយដែលរីករាលដាល
និងអំពើហិង្សាម្តងហើយម្តងទៀតលើគូប្រជែងនយោបាយ ក្រុមប្រឹក្សាភិបាលមិនយល់ស្របនឹង
Meta និងយល់ឃើញថា ការត្រៀមខ្លួនសម្រាប់ការបោះឆ្នោតឆ្នាំ ២០២៣ នៅកម្ពុជា
គឺជាស្ថានភាពនៃអំពើហិង្សាដែលកំពុងបន្ត។

ក្រុមប្រឹក្សាភិបាលកត់សម្គាល់ថា
ទោះបីជាគោលការណ៍ត្រូវបានបង្កើតឡើងបន្ទាប់ពីការវាយប្រហារថ្ងៃទី ៦ ខែមករា ឆ្នាំ ២០២១
មកលើអគារកាពីតូលរបស់សហរដ្ឋអាមេរិកក៏ដោយ
ក៏វាត្រូវបានបង្កើតឡើងដើម្បីផ្តល់ក្របខណ្ឌសម្រាប់ពេលដែល "ការរឹតបន្តឹងស្តង់ដាររបស់ Meta
អាចមិនសមស្របទៅនឹងការបំពាន
ឬមានលក្ខណៈគ្រប់គ្រាន់ក្នុងការកាត់បន្ថយហានិភ័យបង្កគ្រោះថ្នាក់បន្ថែមទៀត
ក្នុងករណីដែលបុគ្គលសាធារណៈបង្ហោះខ្លឹមសារក្នុងអំឡុងពេលមានអំពើហិង្សា
ឬចលាចលស៊ីវិលដែលកំពុងបន្ត"។ ទោះបីជាគោលការណ៍មិនកំណត់និយមន័យឱ្យ
"អំពើហិង្សាដែលកំពុងបន្ត" និង "ភាពចលាចលស៊ីវិល" ក៏ដោយ
ករណីនេះគឺស្របទៅតាមស្មារតីនៃគោលការណ៍នេះយ៉ាងច្បាស់លាស់។
អំពើហិង្សាកំពុងកើតឡើងជាបន្តមិនត្រឹមតែនៅពេលដែលមានឧប្បត្តិហេតុហិង្សាជាបន្តបន្ទា
ប់តែមួយ ឬអំឡុងពេលកើតមានចលាចលស៊ីវិលប៉ុណ្ណោះទេ ប៉ុន្តែក៏នៅក្នុងរយៈពេលនៃ
"សន្តិភាព" ស៊ីវិលផងដែរ
ដែលមេដឹកនាំនយោបាយប្រើប្រាស់ការគំរាមកំហែងនៃអំពើហិង្សាដែលគាំទ្រដោយរដ្ឋ
ដើម្បីបង្ក្រាបទប់ស្កាត់ជាមុនការជំទាស់
និងចលាចលស៊ីវិលតាមរយៈការគាបសង្កត់យ៉ាងទូលំទូលាយ និងអំពើហិង្សាដដែលៗ។
ទោះបីជាក្រុមប្រឹក្សាភិបាលចាត់ទុកករណីនេះថាចាំបាច់ដើម្បីឱ្យ Meta

ធ្វើការបញ្ជាក់ជាសាធារណៈអំពីវិសាលភាពនៃស្ថានភាពដែលក្នុងនោះគោលការណ៍នេះគួរអនុវត្ត ចំពោះបុគ្គលសាធារណៈដែលបង្ហោះខ្លឹមសារនៅក្នុងវេទិការបស់ខ្លួនក៏ដោយ ក៏ខ្លួនយល់ថាវាត្រូវអនុវត្តចំពោះករណីនេះ។

លក្ខខណ្ឌសម្រាប់ការដាក់កំហិតក្រោមគោលការណ៍មានចំនួនបី។ ទីមួយ ភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងប្រវត្តិរបស់បុគ្គលសាធារណៈនៅលើវេទិការបស់ Meta។ ក្រុមប្រឹក្សាភិបាលយល់ឃើញថា ការញុះញង់ឱ្យបញ្ជូនក្រុមជនបង្កហិង្សាទៅកាន់ផ្ទះរបស់ប្រជាជនគឺស្ថិតក្នុងកម្រិតខ្ពស់បំផុតនៃភាពធ្ងន់ធ្ងរ។ ករណីនេះត្រូវបានគាំទ្រដោយប្រវត្តិរបស់លោក ហ៊ុន សែន ក្នុងការញុះញង់ដោយជោគជ័យនូវអំពើហិង្សាលើគូប្រជែងរបស់គាត់ទាំងនៅលើ និងក្រៅវេទិកា និងការដកខ្លឹមសារចេញពីទំព័ររបស់គាត់កាលពីខែធ្នូ ឆ្នាំ ២០២២ ពីបទរំលោភបំពានលើគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់។ លក្ខខណ្ឌទីពីរគឺឥទ្ធិពលសក្តានុពលរបស់បុគ្គលសាធារណៈ និងទំនាក់ទំនងទៅនឹងបុគ្គលដែលចូលរួមក្នុងអំពើហិង្សា។ ជាថ្មីម្តងទៀត ករណីនេះស្ថិតនៅកម្រិតខ្ពស់បំផុត។ លោក ហ៊ុន សែន គឺជានាយករដ្ឋមន្ត្រីដែលមានការគ្រប់គ្រងពេញលេញលើបក្ស មន្ត្រីយោធា មន្ត្រីអនុវត្តច្បាប់ និងប្រព័ន្ធតុលាការនៅកម្ពុជា ព្រមទាំងមានភក្តីភាពខ្ពស់ពីផ្នែកមួយនៃប្រជាជន។ ឥទ្ធិពលរបស់គាត់ត្រូវបានបង្ហាញយ៉ាងច្បាស់ដោយការពិតដែលថាទាំងសុន្ទរកថានេះ និងការញុះញង់ពីមុនបានបណ្តាលឱ្យមានអំពើហិង្សាប្រឆាំងនឹងបុគ្គលគោលដៅរបស់គាត់។ លក្ខខណ្ឌចុងក្រោយ ក៏រួមមានភាពធ្ងន់ធ្ងរនៃអំពើហិង្សា និងការបង្កគ្រោះថ្នាក់ដល់រាងកាយដែលពាក់ព័ន្ធផងដែរ។ សុន្ទរកថានេះបានញុះញង់ឱ្យមានការវាយប្រហារដោយប្រដាប់អាវុធ និងការញុះញង់ពីមុនបានបណ្តាលឱ្យមានការកាប់សម្លាប់គ្នា។ ក្រុមប្រឹក្សាភិបាលក៏កត់សម្គាល់ផងដែរថា ផ្ទុយទៅនឹងការសន្និដ្ឋានរបស់ Meta ដែលថាការគំរាមកំហែងនៅក្នុងសុន្ទរកថារបស់លោក ហ៊ុន សែន គឺ “មិនមានភាពជាក់លាក់” ដោយគាត់បានសំដៅទៅលើសមាជិកគណបក្សប្រឆាំងយ៉ាងហោចណាស់ម្នាក់ដោយការហៅឈ្មោះ។

បន្ថែមពីលើកត្តាដែលបានរាយបញ្ជីក្រោមគោលការណ៍នេះដោយពិចារណាថាតើត្រូវផ្អាកមេដឹកនាំនយោបាយពីវេទិការបស់ខ្លួន និងរយៈពេលនៃការផ្អាកបែបនេះ Meta គួរតែគិតគូរពីបរិបទនយោបាយ និងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសដែលពាក់ព័ន្ធ នៅពេលវាយតម្លៃឥរិយាបថប្រើប្រាស់លើវេទិកា។ ការមើលខ្លឹមសារបែបនោះដែលកំពុងស្ថិតក្រោមការត្រួតពិនិត្យក្នុងសំណុំរឿងនេះ ជាការរំលោភបំពានតែមួយដងលើគោលការណ៍របស់ Meta ដែលត្រូវបានផ្តាច់ចេញពីបរិបទរបស់គោលការណ៍ មិនខ្វល់នឹងការពិតដែលថាសុន្ទរកថានេះ និងអ្នកផ្សេងទៀតចូលចិត្តខ្លឹមសារនេះគឺជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងដែលកំពុងបន្ត និងគ្រោងទុក ដើម្បីបំភិតបំភ័យដែលរួមបញ្ចូលអំពើហិង្សាក្រៅបណ្តាញ។ ជាងនេះទៅទៀត អំពើហិង្សាជាក់ស្តែងបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃការគំរាមកំហែងដែលធ្វើឡើងនៅលើប្រព័ន្ធផ្សព្វ

ផ្សាយសង្គម ដោយផ្តល់សារៈសំខាន់ដល់សកម្មភាពក្រៅប្រព័ន្ធទាំងនេះនៅលើវេទិកា។ ដូចដែលបានកត់សម្គាល់មុននេះ ក្នុងសេចក្តីសម្រេចនេះ លោក ហ៊ុន សែន តែងតែប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្សព្វផ្សាយការគំរាមកំហែងដោយចេតនា និងច្បាស់លាស់ប្រឆាំងនឹងបក្សពួកប្រឆាំង ក៏ដូចជាការបំភិតបំភ័យរបស់គាត់ចំពោះនរណាម្នាក់ដែលគាត់មើលឃើញថាជាការគំរាមកំហែងដល់ការកាន់តំណែងបន្តរបស់គាត់។

តាមព័ត៌មានដែលបង្ហាញជូនក្រុមប្រឹក្សាភិបាល វាហាក់ដូចជាច្បាស់ណាស់ថាលោក ហ៊ុន សែន ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្សព្វផ្សាយការគំរាមកំហែងប្រឆាំងនឹងគូប្រជែងរបស់គាត់ ដោយផ្សព្វផ្សាយការគំរាមកំហែងទាំងនោះឱ្យកាន់តែទូលំទូលាយ និងបង្កគ្រោះថ្នាក់ច្រើនជាងអ្វីដែលគាត់អាចធ្វើបានដោយគ្មានសិទ្ធិចូលប្រើប្រាស់វេទិការបស់ Facebook។ ការប្រើប្រាស់វេទិការបស់លោក ហ៊ុន សែន ដើម្បីញុះញង់ឱ្យមានអំពើហិង្សាលើបក្សពួកប្រឆាំងនយោបាយរបស់គាត់ ដែលត្រូវបានរួមបញ្ចូលក្នុងបរិបទនៃប្រវត្តិរបស់គាត់ធ្លាប់រំលោភសិទ្ធិមនុស្សរបស់រដ្ឋាភិបាល និងការបោះឆ្នោតនាពេលខាងមុខរួមបញ្ចូលគ្នា ដើម្បីទាមទារឱ្យមានវិធានការជាបន្ទាន់។ ក្រុមប្រឹក្សាភិបាលយល់ឃើញថាខ្លឹមសារក្នុងសំណុំរឿងនេះគួរតែត្រូវបានគេមើលឃើញថាជាការបំពានយ៉ាងធ្ងន់ធ្ងរដែលស័ក្តិសមនឹងមានការផ្អាកជាបន្ទាន់ពី Facebook និង Instagram។

ក្រុមប្រឹក្សាភិបាលកត់សម្គាល់ថាបច្ចុប្បន្នក្រុមហ៊ុនមិនជូនដំណឹងដល់សាធារណជននៅពេលដែលទំព័រ ឬគណនីផ្លូវការរបស់មន្ត្រីរដ្ឋាភិបាល ឬរបស់ពួកគេត្រូវបានផ្អាក ឬមានការដកខ្លឹមសារចេញនោះទេ។ Meta គួរតែប្រកាសនៅពេលដែលទំព័រ ឬគណនីរបស់មន្ត្រីរដ្ឋាភិបាលត្រូវបានផ្អាក និងហេតុផលរបស់ក្រុមហ៊ុនសម្រាប់ធ្វើដូច្នេះ។ Meta ក៏គួរពិចារណាលើការរក្សាខ្លឹមសារដែលបានដកចេញសម្រាប់គោលបំណងស្រាវជ្រាវ និងផ្លូវច្បាប់ ព្រមទាំងការចូលប្រើប្រាស់ និងការពិភាក្សាខាងសារព័ត៌មានផងដែរ។

## ៨.២ ការអនុលោមតាមទំនួលខុសត្រូវសិទ្ធិមនុស្សរបស់ Meta

ដូចដែលក្រុមប្រឹក្សាភិបាលបានយល់ឃើញខាងលើ គោលការណ៍ផ្ទាល់ខ្លួនរបស់ Meta តម្រូវឱ្យសារបង្ហោះរបស់លោក ហ៊ុន សែន គួរតែត្រូវបានដកចេញ។ ក្រុមប្រឹក្សាភិបាលក៏បានសន្និដ្ឋានថា គោលការណ៍របស់ Meta លើការរឹតបន្តឹងគណនីរបស់បុគ្គលសាធារណៈក្នុងអំឡុងពេលមានចលាចលស៊ីវិលស័ក្តិសមនឹងមានការផ្អាកលោក ហ៊ុន សែន ពីការប្រើប្រាស់វេទិការបស់ Meta។ ការអនុញ្ញាតឱ្យខ្លឹមសារនេះបន្តមាននៅលើ Facebook ក៏ដូចជាការបន្តប្រើប្រាស់វេទិការបស់ Meta របស់លោក ហ៊ុន សែន ដើម្បីញុះញង់ឱ្យមានអំពើហិង្សា គឺវាផ្ទុយនឹងទំនួលខុសត្រូវសិទ្ធិមនុស្សរបស់ក្រុមហ៊ុន។ ករណីនេះគឺមានភាពពាក់ព័ន្ធជាពិសេស ដោយសារតែហានិភ័យនៃខ្លឹមសារនេះគំរាមកំហែងដល់សិទ្ធិក្នុងការបោះឆ្នោត

និងសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ (ICCPR មាត្រា ២៥) សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី (ICCPR មាត្រា ២១) សិទ្ធិទទួលបានសន្តិសុខរាងកាយ (ICCPR មាត្រា ៩) និងសិទ្ធិរស់រានមានជីវិត (ICCPR , មាត្រា ៦) នៅកម្ពុជា។ នៅក្នុងការវិភាគខាងក្រោម ក្រុមប្រឹក្សាភិបាលវាយតម្លៃការរឹតបន្តឹងសុន្ទរកថានេះ ដោយគិតពីទំនួលខុសត្រូវរបស់ Meta ក្នុងការការពារសេរីភាពនៃការបញ្ចេញមតិ (ICCPR មាត្រា ១៩)។

1. សេរីភាពនៃការបញ្ចេញមតិ (មាត្រា ១៩ ICCPR)

មាត្រា ១៩ កថាខណ្ឌ ២, នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ការពារ "ការបញ្ចេញមតិ និងការទទួលការប្រាស្រ័យទាក់ទងនៃគ្រប់ទម្រង់នៃគំនិត និងមតិយោបល់ដែលមានសមត្ថភាពបញ្ជូនទៅកាន់អ្នកដទៃ" រួមទាំងទាក់ទងទៅនឹងនយោបាយ កិច្ចការសាធារណៈ និង សិទ្ធិមនុស្ស (សេចក្តីពន្យល់ទូទៅលេខ ៣៤ (ឆ្នាំ ២០១១), គណៈកម្មាធិការសិទ្ធិមនុស្ស, កថាខណ្ឌ ១១-១២)។ លើសពីនេះទៀត គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ថា "ការប្រាស្រ័យទាក់ទងដោយសេរីនៃព័ត៌មាន និងគំនិតអំពីបញ្ហាសាធារណៈ និងនយោបាយរវាងប្រជាពលរដ្ឋ បេក្ខជន និងអ្នកតំណាងជាប់ឆ្នោត គឺជារឿងចាំបាច់" (សេចក្តីពន្យល់ទូទៅលេខ ៣៤ កថាខណ្ឌ ២០)។

នៅពេលដែលការរឹតបន្តឹងលើការបញ្ចេញមតិត្រូវបានកំណត់ដោយរដ្ឋមួយ ការរឹតបន្តឹងទាំងនោះត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវនៃនីត្យានុកូលភាព គោលបំណងស្របច្បាប់ និងភាពចាំបាច់ និងភាពសមស្រប (មាត្រា ១៩ កថាខណ្ឌ ៣, ICCPR)។ ជារឿយៗ លក្ខខណ្ឌតម្រូវទាំងនេះត្រូវបានហៅថា "ការធ្វើតេស្តបីផ្នែក"។ ក្រុមប្រឹក្សាភិបាលប្រើប្រាស់ក្របខណ្ឌនេះ ដើម្បីបកស្រាយការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តរបស់ Meta អំពីសិទ្ធិមនុស្ស ទាំងទាក់ទងនឹងសេចក្តីសម្រេចលើខ្លឹមសារបុគ្គលដែលស្ថិតក្រោមការត្រួតពិនិត្យ និងវិធីសាស្ត្រកាន់តែទូលំទូលាយរបស់ Meta ចំពោះអភិបាលកិច្ចខ្លឹមសារ។ ដូចដែលអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសេរីភាពនៃការបញ្ចេញមតិបានបញ្ជាក់ថា ទោះបីជា "ក្រុមហ៊ុនមិនមានកាតព្វកិច្ចរបស់រដ្ឋាភិបាលក៏ដោយ ក៏ឥទ្ធិពលរបស់រដ្ឋាភិបាលគឺជាប្រភេទដែលតម្រូវឱ្យពួកគេវាយតម្លៃបញ្ហាដូចគ្នាទាក់ទងនឹងកិច្ចការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់អ្នកប្រើប្រាស់របស់ខ្លួន" (A/៧៤/៤៨៦, កថាខណ្ឌ ៤១)។ ក្នុងករណីនេះ ក្រុមប្រឹក្សាភិបាលបានអនុវត្តការធ្វើតេស្តបីផ្នែក ដើម្បីវាយតម្លៃថាតើទាំងការដកចេញនូវខ្លឹមសារ និងការផ្អាករបស់លោក ហ៊ុន សែន ខណៈពេលដែលមានភាពសមស្របតាមគោលការណ៍របស់ Meta មានលក្ខណៈស្របគ្នានឹងការទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងកិច្ចការពារសេរីភាពនៃការបញ្ចេញមតិឬទេ។

## *I. និត្យានុកូលភាព (ភាពច្បាស់លាស់ និងលទ្ធភាពអាចប្រើប្រាស់បាននៃច្បាប់)*

គោលការណ៍នៃនីត្យានុកូលភាពក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ តម្រូវឱ្យច្បាប់ដែលដាក់កំហិតលើការបញ្ចេញមតិមានភាពច្បាស់លាស់ និងអាចចូលប្រើប្រាស់បានជាសាធារណៈ (សេចក្តីពន្យល់ទូទៅលេខ ៣៤ កថាខណ្ឌ ២៥)។ ច្បាប់ដែលដាក់កំហិតលើការបញ្ចេញមតិ "មិនអាចផ្តល់ឆន្ទានុសិទ្ធិដោយគ្មានការដាក់កំហិតសម្រាប់ការរឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិលើបុគ្គលដែលត្រូវបានចោទប្រកាន់ការប្រតិបត្តិ [របស់ខ្លួន]" និង "ផ្តល់ការណែនាំគ្រប់គ្រាន់ដល់បុគ្គលដែលត្រូវបានចោទប្រកាន់ពីការប្រតិបត្តិរបស់ខ្លួន ដើម្បីអាចឱ្យពួកគាត់ដឹងថាតើប្រភេទនៃការបញ្ចេញមតិណាខ្លះត្រូវបានរឹតបន្តឹងយ៉ាងត្រឹមត្រូវ និងប្រភេទណាខ្លះដែលមិនត្រូវបានរឹតបន្តឹងយ៉ាងត្រឹមត្រូវ" *(Ibid)*។ ដោយបានអនុវត្តចំពោះច្បាប់ដែលគ្រប់គ្រងសន្ទរកថាលើអ៊ីនធឺណិត អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសេរីភាពនៃការបញ្ចេញមតិបានបញ្ជាក់ថា សន្ទរកថាទាំងនោះគួរតែមានភាពច្បាស់លាស់ និងជាក់លាក់ (A/HRC/៣៨/៣៥, កថាខណ្ឌ ៤៦)។ អ្នកដែលប្រើប្រាស់វេទិការបស់ Meta គួរតែអាចចូលប្រើ និងយល់ពីច្បាប់ ហើយអ្នកពិនិត្យមើលខ្លឹមសារគួរតែមានការណែនាំច្បាស់លាស់លើការអនុវត្តច្បាប់របស់ខ្លួន។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា លោក ហ៊ុន សែន និងអ្នកដែលរក្សាវត្តមានរបស់គាត់លើប្រព័ន្ធផ្សព្វផ្សាយសង្គមនឹងអាចកំណត់បានយ៉ាងងាយស្រួលថាខ្លឹមសារនោះបានបំពានលើការហាមឃាត់របស់ស្តង់ដារសហគមន៍អំពីអំពើហិង្សា និងការញុះញង់លើសន្ទរកថាដែលគំរាមកំហែង ជាពិសេសទាក់ទងនឹងការបោះឆ្នោតនាពេលខាងមុខ។ ដើម្បីគំរាមកំហែងអ្នករិះគន់ដោយ "ដំបង" និងដោយការវាយដំដោយបក្សព័ន្ធគឺផ្ទុយនឹងច្បាប់យ៉ាងច្បាស់លាស់។ ដូចគ្នានេះដែរ គោលការណ៍របស់ Meta លើការរឹតបន្តឹងគណនីនៃបុគ្គលសាធារណៈ បញ្ជាក់យ៉ាងច្បាស់ថា ការបំពានធ្ងន់ធ្ងរពីបុគ្គលសាធារណៈដែលនាំឱ្យមានអំពើហិង្សា និងការបង្កគ្រោះថ្នាក់ដល់រាងកាយ នៅក្នុងបរិបទកាន់តែទូលំទូលាយនៃអំពើហិង្សាដែលកំពុងបន្ត ស័ក្តិសមនឹងទទួលបានការផ្អាក។ ដូចដែលបានកត់សម្គាល់ខាងលើក្រុមប្រឹក្សាភិបាលយល់ឃើញថា ដូចដែលបានព្រាងបច្ចុប្បន្ន គោលការណ៍នេះត្រូវបានអនុវត្តចំពោះសំណុំរឿងនេះ។ ទោះជាយ៉ាងណាក៏ដោយ Meta គួរតែបញ្ជាក់ជាសាធារណៈអំពីវិសាលភាពនៃគោលការណ៍នេះ។

## *II. គោលបំណងស្របច្បាប់*

ស្តង់ដារសហគមន៍ស្តីពីអំពើហិង្សា និងការញុះញង់ ត្រូវបានរៀបចំឡើងក្នុងគោលបំណង "ទប់ស្កាត់គ្រោះថ្នាក់ក្រៅបណ្តាញដែលអាចកើតមាន" និងដកចេញនូវខ្លឹមសារដែលបង្ក "ហានិភ័យពិតប្រាកដនៃគ្រោះថ្នាក់ដល់រាងកាយ

ឬការគំរាមកំហែងដោយផ្ទាល់ចំពោះសុវត្ថិភាពសាធារណៈ”។ លើសពីនេះទៀត គោលការណ៍របស់ Meta លើការរឹតបន្តឹងគណនីនៃបុគ្គលសាធារណៈត្រូវបានអនុវត្តនៅពេលដែល “ការរឹតបន្តឹងស្តង់ដារអាចមិនសមស្របទៅនឹងការរំលោភបំពាន ឬគ្រប់គ្រាន់ដើម្បីកាត់បន្ថយហានិភ័យបង្កគ្រោះថ្នាក់បន្ថែមទៀត”។ ការហាមឃាត់ការអំពាវនាវឱ្យមានអំពើហិង្សា និងការគំរាមកំហែងនៃការចាប់ខ្លួនតាមអំពើចិត្តនៅលើវេទិកាដើម្បីធានាសុវត្ថិភាពរបស់ប្រជាជនគឺជាគោលបំណងស្របច្បាប់មួយនៅក្រោមមាត្រា ១៩ កថាខណ្ឌ ៣, ដូចដែលវាការពារ “សិទ្ធិរបស់អ្នកដទៃ” ក្នុងការរស់រានមានជីវិត (ICCPR មាត្រា ៦) និងសន្តិសុខរាងកាយប្រឆាំងនឹងការចាប់ខ្លួន និងការឃុំខ្លួនតាមអំពើចិត្ត (ICCPR មាត្រា ៩ កថាខណ្ឌ ១). ជាពិសេសនៅក្នុងដំណើរការបោះឆ្នោត គោលការណ៍ទាំងពីរនេះក៏អាចព្យាយាមសម្រេចគោលបំណងស្របច្បាប់នៃកិច្ចការពារសិទ្ធិរបស់អ្នកដទៃក្នុងការជួបប្រជុំដោយសន្តិវិធី (ICCPR មាត្រា ២១) និងសិទ្ធិក្នុងការការបោះឆ្នោត និងសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ (ICCPR មាត្រា ២៥)។

### *III. ភាពចាំបាច់ និងភាពសមស្រប*

គោលការណ៍នៃភាពចាំបាច់ និងភាពសមស្របចែងថាការរឹតបន្តឹងទាំងឡាយលើសេរីភាពនៃការបញ្ចេញមតិ “ត្រូវតែមានភាពសមស្របដើម្បីសម្រេចបាននូវតួនាទីការពារនៃការរឹតបន្តឹងទាំងនោះ, ការរឹតបន្តឹងទាំងនោះត្រូវតែជាឧបករណ៍ដែលរំខានតិចបំផុតក្នុងចំណោមឧបករណ៍ដែលអាចសម្រេចបាននូវតួនាទីការពារនៃការរឹតបន្តឹងទាំងនោះ [និង] ការរឹតបន្តឹងទាំងនោះត្រូវតែសមស្របទៅនឹងអត្ថប្រយោជន៍ដែលត្រូវការពារ” (សេចក្តីពន្យល់ទូទៅលេខ ៣៤ កថាខណ្ឌ ៣៤)។

នៅពេលវិភាគហានិភ័យដែលបង្កឡើងដោយខ្លឹមសារហិង្សា ជាជម្មតាក្រុមប្រឹក្សាភិបាលត្រូវបានតំរែតម្រង់ដោយការធ្វើតេស្តកត្តាប្រាំមួយដែលបានពណ៌នានៅក្នុងផែនការសកម្មភាពរបស់ Rabat ដែលបរិយាយអំពីការតស៊ូមតិនៃសេចក្តីស្អប់ខ្ពើមជាតិសាសន៍ ពូជសាសន៍ ឬសាសនាដែលបង្កើតជាការញុះញង់ឱ្យមានអរិភាព ការរើសអើង ឬអំពើហិង្សា។ ផ្អែកលើការវាយតម្លៃលើកត្តាពាក់ព័ន្ធ ជាពិសេសអ្នកនិយាយ បរិបទ និងវិសាលភាពនៃសកម្មភាពសុន្ទរកថា ដែលបានពណ៌នាបន្ថែមខាងក្រោម ក្រុមប្រឹក្សាភិបាលយល់ឃើញថា ការដកចេញនូវខ្លឹមសារញុះញង់របស់លោក ហ៊ុន សែន គឺធ្វើឡើងស្របតាមទំនួលខុសត្រូវសិទ្ធិមនុស្សរបស់ Meta ដោយសារខ្លឹមសារនោះបង្កគ្រោះថ្នាក់ដែលជិតនឹងកើតមាន និងទំនងជាកើតមាន។ ការដកខ្លឹមសារចេញគឺជាការដាក់កំណត់ចាំបាច់ និងសមស្របលើការបញ្ចេញមតិ ដើម្បីការពារសិទ្ធិរស់រានមានជីវិត និងសន្តិសុខរាងកាយរបស់មនុស្ស រួមទាំងការពារសមាជិកបក្សប្រឆាំងពីអំពើហិង្សា និងការធ្វើទុក្ខបុកម្នេញដែលអាចកើតមាន។

សុន្ទរកថាដែលបង្ហាញក្នុងវីដេអូដែលបានបង្ហោះនោះ
ត្រូវបានថ្លែងដោយប្រមុខរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា
ដែលជាបុគ្គលសាធារណៈដែលបានកាន់អំណាចតាំងពីឆ្នាំ ១៩៨៥ និងមានយុត្តាធិការ
និងសិទ្ធិអំណាចយ៉ាងសំខាន់។ ក្នុងន័យនេះ សុន្ទរកថាគឺស្មើនឹងសកម្មភាពរបស់រដ្ឋ។
ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងផ្នែកសារតារនៃសំណុំរឿង រដ្ឋាភិបាលរបស់លោក ហ៊ុន សែន
ត្រូវបានគេរាយការណ៍ថាបានប្រើប្រាស់ទាំងអំពើហិង្សាលើរាងកាយ និងប្រព័ន្ធតុលាការកម្ពុជា
ដើម្បីបំបិទមាត់ និងធ្វើទុក្ខបុកម្នេញអ្នកប្រឆាំង និងសមាជិកបក្សប្រឆាំង។
ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីសម្រេចសំណុំរឿង
"ការផ្អាកសិទ្ធិចូលប្រើប្រាស់របស់អតីតប្រធានាធិបតី លោកត្រាំ" (២០២១-០០១-FB-FBR)
កត្តាទាំងនេះបង្កើនទាំងកម្រិតនៃហានិភ័យបង្កគ្រោះថ្នាក់ដែលទាក់ទងនឹងសេចក្តីថ្លែងការណ៍
របស់គាត់ និងផលប្រយោជន៍សាធារណៈនៅក្នុងសុន្ទរកថារបស់គាត់។

សុន្ទរកថានេះត្រូវបានធ្វើឡើងក្នុងរយៈពេលជាងប្រាំមួយខែមុនការបោះឆ្នោតសភាខែកក្កដា
ឆ្នាំ ២០២៣ នៅកម្ពុជា និងបានលើកឡើងពីបញ្ហាផលប្រយោជន៍សាធារណៈ
រួមទាំងការពិភាក្សាបន្ថែមទៀតអំពីការបោះឆ្នោត និងហេដ្ឋារចនាសម្ព័ន្ធជាតិ។
ក្រុមប្រឹក្សាភិបាលកត់សម្គាល់ឃើញថាប្រជាជននៅក្នុងប្រទេសកម្ពុជាមានសិទ្ធិទទួលបានព័ត៌
មានអំពីបញ្ហាទាំងនេះតាមរយៈមធ្យោបាយផ្សេងទៀត
រួមទាំងគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងទៀត
និងការរាយការណ៍អំពីសុន្ទរកថាដែលមិនបានលើកឡើងពីការគំរាមកំហែង។
ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ពាក្យដូចជា "ដំបង"
ដែលបរិបទបញ្ជាក់យ៉ាងច្បាស់គឺជាការសំដៅទៅលើអាវុធ និង "ការបញ្ជូនក្មេងទំនើងទៅផ្ទះ
[របស់អ្នក]" ឬ "ចំណាត់ការផ្លូវច្បាប់" រួមទាំងការចាប់ខ្លួនទាំងកណ្តាលអធ្រាត្រ
នៅពេលហៅឈ្មោះមេដឹកនាំគណបក្សប្រឆាំង គឺស្មើនឹងការញុះញង់មានអំពើហិង្សា និងការ
គំរាមចាប់ខ្លួនតាមអំពើចិត្ត ដើម្បីរារាំងការមិនចុះសម្រុងផ្នែកនយោបាយ និងធ្វើបក្ស
ពួកប្រឆាំងចុះខ្សោយ។

ក្រោមហេតុផលនៃការសម្រេចចិត្តរបស់ខ្លួន Meta បានបន្តថា
"ការគំរាមកំហែងក្នុងករណីនេះគឺមិនជាក់លាក់
និងមិនមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ
ឬព្រឹត្តិការណ៍ហិង្សាដែលកំពុងកើតមានបន្តនោះទេ"។
ក្រុមប្រឹក្សាភិបាលមិនទទួលយកការកំណត់របស់ Meta
ចំពោះការគំរាមកំហែងថាមិនជាក់លាក់នោះទេ។ នៅក្នុងបរិបទ
ការសំដៅដោយបញ្ជិតបញ្ជៀងនៅតែអាចយល់ថាមានអត្ថន័យជាក់លាក់។ ត្រង់នេះ
ការគំរាមកំហែងត្រូវបានបង្ហាញឱ្យឃើញច្បាស់តាមរយៈទិដ្ឋភាពពីខាងក្រោយនៃការបោះឆ្នោត
ជិតមកដល់ និងការកំណត់អត្តសញ្ញាណគូប្រជែងនយោបាយរបស់លោក ហ៊ុន សែន

ជាគោលដៅរបស់ខ្លួន។ លើសពីនេះ ដោយសារប្រវត្តិនៃអំពើហិង្សាពីសំណាក់អ្នកគាំទ្រលោក ហ៊ុន សែន និងការបំភិតបំភ័យដល់តស្សូរជនគណបក្សប្រឆាំង ក្រុមប្រឹក្សាភិបាលយល់ឃើញថា ការអំពាវនាវឱ្យមានអំពើហិង្សាណាមួយដែលធ្វើឡើងដោយលោកនាយករដ្ឋមន្ត្រីល្មមនឹងជឿបាន និងមានឥទ្ធិពលដ៏គួរឱ្យខ្លាច។ នេះជាការពិត ជាពិសេសដោយសារតែរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងទាំងស្រុងលើមធ្យោបាយនៃអំពើហិង្សា បន្ថែមលើអំណាចអនុគ្រោះរបស់ខ្លួន។

ការបោះឆ្នោតគឺជាផ្នែកមួយដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ហើយក្រុមប្រឹក្សាភិបាលយកចិត្តទុកដាក់ចំពោះការបោះឆ្នោតសភានៅកម្ពុជានាពេលខាងមុខ។ អត្ថាធិប្បាយសាធារណៈបានសង្កត់ធ្ងន់ថាសុន្ទរកថារបស់លោក ហ៊ុន សែន គួរតែត្រូវបានវាយតម្លៃថា “នៅក្នុងបរិបទទាំងមូលនៃស្ថានភាពសិទ្ធិមនុស្សមិនល្អ និងឱនភាពប្រជាធិបតេយ្យនៅកម្ពុជានៅមុនការបោះឆ្នោតខែកក្កដា ឆ្នាំ ២០២៣ និងអំពើហិង្សា និងការបង្ក្រាបដែលកំពុងបន្តលើគូប្រជែងនយោបាយដែលពាក់ព័ន្ធ” ដែលនាំឱ្យមាន “ហានិភ័យពិតប្រាកដនៃការរំលោភបំពានសិទ្ធិមនុស្ស និងគ្រោះថ្នាក់ផ្សេងទៀតដល់បុគ្គលដែលពាក់ព័ន្ធ” (អាត្ថាធិប្បាយ ICJ, PC-១១០៣៨ សូមមើលផងដែរនូវ អត្ថាធិប្បាយ HRF, PC-១១០៤១)។ [របាយការណ៍ឆ្នាំ ២០២២] របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានព្រមានថា គណបក្សនយោបាយមួយចំនួនធំដែលបានចូលរួមការបោះឆ្នោតមូលដ្ឋានឆ្នាំ ២០២២ គឺ “ជារូបភាពបំភាន់ភ្នែកដែលមិនមែនជាការពិត” ហើយចាប់តាំងពីការបោះឆ្នោតឆ្នាំ ២០១៧ មក “ការប្រកួតប្រជែងសម្រាប់ពហុនិយមប្រជាធិបតេយ្យត្រូវបានបំផ្លាញយ៉ាងខ្លាំង ហើយការដាក់គំនាបពីការគ្រប់គ្រងដោយបក្សតែមួយបានធ្វើសកម្មភាពយ៉ាងឃោឃៅលើទីលាននយោបាយ”។

តាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល សុន្ទរកថាដែលថ្លែងដោយមន្ត្រីសាធារណៈដែលមានប្រវត្តិគាបសង្កត់ផ្នែកនយោបាយ អំពើហិង្សា និងការបំភិតបំភ័យ នៅមុនការបោះឆ្នោត រួមចំណែកដល់យុទ្ធនាការកាន់តែទូលំទូលាយដើម្បីញុះញង់ឱ្យមានអំពើហិង្សា ក៏ដូចជាការបំភិតបំភ័យ និងបំបិទមាត់អ្នកប្រឆាំង និងបក្សពួកប្រឆាំង។ ហេតុដូច្នេះហើយ ក្រុមប្រឹក្សាភិបាលយល់ឃើញថា ការដកខ្លឹមសារចេញក្រោមគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់គឺចាំបាច់ ក្នុងន័យថាគ្មានវិធានការណាមួយផ្សេងទៀតដែលរឹតបន្តឹងលើសេរីភាពនៃការបញ្ចេញមតិនឹងសមស្របដើម្បីការពារសិទ្ធិរបស់មនុស្ស។ ក្រុមប្រឹក្សាភិបាលក៏សន្និដ្ឋានថាការដកចេញបែបនេះគឺសមស្រប ដែលផ្តល់លទ្ធភាព និងហានិភ័យបង្កគ្រោះថ្នាក់ដល់សិទ្ធិមនុស្សដែលរងផលប៉ះពាល់ក្នុងករណីនេះ។

ដោយសារតែបរិបទនៃប្រវត្តិធ្លាប់រំលោភបំពានសិទ្ធិមនុស្សរបស់លោក ហ៊ុន សែន ការបំភិតបំភ័យ និងការគាបសង្កត់របស់លោកមកលើគូប្រជែងនយោបាយ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្សព្វផ្សាយការគំរាមកំហែងរបស់គាត់ ក្រុមប្រឹក្សាភិបាលយល់ឃើញថា ការដកខ្លឹមសារនេះចេញមិនគ្រប់គ្រាន់ដើម្បីគោរពសិទ្ធិអ្នកដទៃនៅក្នុងករណីនេះនៅឡើយទេ ហើយថាការផ្អាករបស់គាត់គឺចាំបាច់។ គ្រាន់តែដកខ្លឹមសារចេញ គែមិនអាចទប់ស្កាត់ការបំពាន និងការញុះញង់ឱ្យកើតមានអំពើហិង្សានាពេលខាងមុខបានទេ ដែលវាមានគ្រោះថ្នាក់ជាពិសេសដោយសារបរិបទថ្មីៗ និងការបោះឆ្នោតនាពេលខាងមុខ។ ដូច្នេះ ក្រុមប្រឹក្សាក៏យល់ឃើញថា ការផ្អាកទំព័រ Facebook និងគណនី Instagram ផ្លូវការរបស់លោក ហ៊ុន សែន គឺជាការសមស្រប។

## 9. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យបដិសេធសេក្តីសម្រេចរបស់ Meta ក្នុងការបន្តឱ្យមានខ្លឹមសារនេះ ដោយតម្រូវឱ្យដកសារបង្ហោះនោះចេញ។

## 10. អនុសាសន៍

A. <u>គោលការណ៍ខ្លឹមសារ</u>

1. Meta គួរតែបញ្ជាក់ឱ្យច្បាស់ថា គោលការណ៍របស់ខ្លួនសម្រាប់រឹតបន្តឹងគណនីរបស់បុគ្គលសាធារណៈអនុវត្តចំពោះបរិបទ ដែលប្រជាពលរដ្ឋស្ថិតនៅក្រោមការគំរាមកំហែងជាបន្តបន្ទាប់ពីអំពើហិង្សាសងសឹកពីរដ្ឋាភិបាលរបស់ពួកគេ។ គោលការណ៍នេះគួរតែបញ្ជាក់ឱ្យច្បាស់ថា គោលការណ៍នេះមិនត្រូវបានរឹតបន្តឹងត្រឹមតែឧបទ្ទវហេតុតែមួយនៃភាពចលាចលស៊ីវិល ឬអំពើហិង្សាប៉ុណ្ណោះទេ ហើយថាគោលការណ៍នេះត្រូវបានអនុវត្ត ក្នុងករណីដែលការបញ្ចេញមតិនយោបាយត្រូវបានគាបសង្កត់ជាមុន ឬឆ្លើយតបដោយអំពើហិង្សា ឬការគំរាមកំហែងនៃអំពើហិង្សាពីរដ្ឋ។ ក្រុមប្រឹក្សាភិបាលនឹងចាត់ទុកថាអនុសាសន៍នេះត្រូវបានអនុវត្តនៅពេលដែលក្របខណ្ឌសាធារណៈរបស់ Meta សម្រាប់ការរឹតបន្តឹងគណនីនៃបុគ្គលសាធារណៈត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីបញ្ចាញពីការបញ្ជាក់ទាំងនេះ។

2. Meta គួរតែធ្វើបច្ចុប្បន្នភាពគោលការណ៍ស្តីពីការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មានរបស់ខ្លួនដើម្បីបញ្ជាក់ថាខ្លឹមសារដែលញុះញង់ឱ្យមានអំពើហិង្សាដោយផ្ទាល់គឺមិនមានសិទ្ធិទទួលបានការអត់ឱនសម្រាប់ភាពស័ក្តិសមជាព័ត៌មាននោះទេ

ដែលអាចនឹងមានការលើកលែងពីគោលការណ៍ដែលមានស្រាប់។ ក្រុមប្រឹក្សាភិបាលនឹងចាត់ទុកថាអនុសាសន៍នេះត្រូវបានអនុវត្តនៅពេលដែល Meta បោះផ្សាយគោលការណ៍ដែលបានធ្វើបច្ចុប្បន្នភាពលើខ្លឹមសារព័ត៌មានដែលស័ក្តិសមជាព័ត៌មានដែលកំណត់យ៉ាងច្បាស់អំពីការដាក់កំណត់នេះលើការអត់ឱន។

B. <u>ការអនុវត្តច្បាប់</u>

3. Meta គួរតែផ្អាកជាបន្ទាន់នូវទំព័រ Facebook និងគណនី Instagram ផ្លូវការរបស់នាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន ក្នុងរយៈពេលយ៉ាងហោចណាស់ប្រាំមួយខែ ក្រោមគោលការណ៍របស់ Meta ស្តីពីការរឹតបន្តឹងគណនីរបស់បុគ្គលសាធារណៈអំឡុងពេលមានចលាចលស៊ីវិល។ ក្រុមប្រឹក្សាភិបាលនឹងចាត់ទុកអនុសាសន៍នេះត្រូវបានអនុវត្ត នៅពេលដែល Meta ផ្អាកគណនី និងប្រកាសជាសាធារណៈថាខ្លួនបានធ្វើដូច្នេះ។

4. Meta គួរតែធ្វើបច្ចុប្បន្នភាពប្រព័ន្ធកំណត់អាទិភាពនៃការពិនិត្យមើលរបស់ខ្លួន ដើម្បីធានាថាខ្លឹមសារពីប្រមុខរដ្ឋ និងសមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាលសក្តានុពលដែលបានបំពានលើគោលការណ៍ស្តីពីអំពើហិង្សា និងការញុះញង់ត្រូវបានផ្តល់អាទិភាពជាប់លាប់សម្រាប់ការពិនិត្យមើលភ្លាមៗដោយមនុស្ស។ ក្រុមប្រឹក្សាភិបាលនឹងចាត់ទុកថាអនុសាសន៍ត្រូវបានអនុវត្ត នៅពេលដែល Meta បញ្ចេញព័ត៌មានលម្អិតអំពីការផ្លាស់ប្តូរប្រព័ន្ធចំណាត់ថ្នាក់ពិនិត្យមើលរបស់ខ្លួន និងបង្ហាញពីរបៀបដែលការផ្លាស់ប្តូរទាំងនោះនឹងធានាបាននូវការពិនិត្យមើលសម្រាប់ករណីនេះ និងខ្លឹមសារស្រដៀងគ្នាពីប្រមុខរដ្ឋ និងសមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាល។

5. Meta គួរតែអនុវត្តការផ្លាស់ប្តូរគោលការណ៍ណែនាំផលិតផល និង/ឬគោលការណ៍ណែនាំប្រតិបត្តិការ ដែលអនុញ្ញាតឱ្យមានការពិនិត្យមើលត្រឹមត្រូវជាងមុនលើវីដេអូទម្រង់វែង (ឧ. ការប្រើក្បួនដោះស្រាយសម្រាប់ព្យាកររយៈពេលនៃការបំពាន ដែលធានាបាននូវពេលវេលាពិនិត្យមើលសមស្របជាមួយនឹងរយៈពេលវីដេអូ ដែលអនុញ្ញាតឱ្យវីដេអូចាក់ ១,៥x ឬលឿនជាង ២x ។ល។) ក្រុមប្រឹក្សាភិបាលនឹងចាត់ទុកថាអនុសាសន៍នេះត្រូវបានអនុវត្ត នៅពេលដែល Meta ចែករំលែកនីតិវិធីសម្របសម្រួលវីដេអូទម្រង់វែងថ្មីរបស់ខ្លួនជាមួយក្រុមប្រឹក្សាភិបាល រួមទាំងម៉ាទ្រិកសម្រាប់បង្ហាញការកែលម្អក្នុងសុក្រិតភាពនៃការពិនិត្យមើលសម្រាប់វីដេអូទម្រង់វែង។

C. <u>តម្លាភាព</u>

6. ក្នុងករណីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងក្នុងគ្រប់ចំណាត់ការកម្រិតគណនីប្រឆាំងនឹងប្រមុខរដ្ឋ និងសមាជិកជាន់ខ្ពស់របស់រដ្ឋាភិបាល Meta គួរតែបង្ហាញជាសាធារណៈអំពីវិសាលភាពនៃចំណាត់ការ និងហេតុផលនៅពីក្រោយការសម្រេចចិត្តរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាលនឹងចាត់ទុកថាអនុសាសន៍នេះត្រូវបានអនុវត្តនៅពេលដែល Meta បញ្ចេញព័ត៌មាននេះដល់លោក ហ៊ុន សែន និងប្ដេជ្ញាធ្វើដូច្នេះសម្រាប់ការអនុវត្តនាពេលខាងមុខប្រឆាំងនឹងប្រមុខរដ្ឋ និងសមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាលទាំងអស់។

***កំណត់សន្យាតាមនីតិវិធី៖**

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបានរៀបចំឡើងដោយក្រុមសមាជិកចំនួនប្រាំនាក់ និងត្រូវបានអនុម័តដោយភាគច្រើននៃក្រុមប្រឹក្សាភិបាល។ សេក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលមិនចាំបាច់តំណាងឱ្យទស្សនៈផ្ទាល់ខ្លួនរបស់សមាជិកទាំងអស់នោះទេ។

សម្រាប់សេចក្ដីសម្រេចលើសំណុំរឿងនេះ ការស្រាវជ្រាវឯករាជ្យត្រូវបានបង្គាប់តាងនាមឱ្យក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលមានការគាំទ្រជាជំនួយពីវិទ្យាស្ថានស្រាវជ្រាវឯករាជ្យដែលមានទីស្នាក់ការនៅសាកលវិទ្យាល័យ Gothenburg ដែលពឹងផ្អែកលើក្រុមអ្នកវិទ្យាសាស្ត្រសង្គមជាង ៥០ នាក់នៅលើទ្វីបចំនួនប្រាំមួយ ក៏ដូចជាអ្នកជំនាញនៅប្រទេសជាង ៣.២០០ មកពីជុំវិញពិភពលោក។ ក្រុមប្រឹក្សាភិបាលក៏មានការគាំទ្រជាជំនួយពី Duco Advisors ដែលជាក្រុមហ៊ុនប្រឹក្សាដែលផ្ដោតលើចំណុចប្រសព្វនៃភូមិសាស្ត្រនយោបាយ ទំនុកចិត្ត និងសុវត្ថិភាព និងបច្ចេកវិទ្យា។ Memetica ដែលជាស្ថាប័នដែលចូលរួមក្នុងការស្រាវជ្រាវប្រភពបើកចំហលើនិន្នាការប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏បានផ្ដល់ការវិភាគផងដែរ។ អ្នកជំនាញភាសាវិទ្យាត្រូវបានផ្ដល់ដោយ Lionbridge Technologies, LLC ដែលមានអ្នកឯកទេសស្ទាត់ជំនាញជាង ៣៥០ ភាសា និងធ្វើការពីទីក្រុងចំនួន ៥.០០០ ជុំវិញពិភពលោក។